រាជបណ្ឌិត្យសភាកម្ពុជា

# វិវាទ កម្ពុជា-ថៃ (២០០៦-២០១២)

# Cambodia-Thailand Conflict (2006-2012)

ភាគ ៣

វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា

ដោយ៖ វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ

២០១៣

រាជបណ្ឌិត្យសភាកម្ពុជា

# វិវាទ កម្ពុជា-ថៃ (២០០៦-២០១២)

# Cambodia-Thailand Conflict (2006-2012)

យង់ ពៅ

និក្ខេបបទបណ្ឌិតវិទ្យាសាស្ត្រនយោបាយ

ឯកទេស ៖ វិទ្យាសាស្ត្រនយោបាយ

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត សុខ ទូច

ឆ្នាំ ២០១២

# មាតិកា

ទំព័រ

ឧទ្ទិសស្នាដៃ ..... viii
សេចក្តីថ្លែងអំណរគុណ ..... ix
អំណះអំណាង ..... x
ពាក្យប្រើជាអក្សរកាត់ ..... xi
មូលន័យសង្ខេប ..... xiii
Abstract ..... xiv
សង្ខេបនិក្ខេបបទ ..... xv
Summary ..... xxx
អារម្ភកថា ..... xlvi

សេចក្តីផ្តើម ..... ១

១- លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១
២- ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ៣
៣- គោលបំណងនៃការស្រាវជ្រាវ ..... ៣
៤- ដែនកំណត់ និង វិសាលភាពនៃការសិក្សាស្រាវជ្រាវ ..... ៣
៥- វិធីសាស្ត្រស្រាវជ្រាវ ..... ៤
៦- សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ..... ៤
៧- រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ..... ៥

**ជំពូក១**
**ទិដ្ឋភាពទូទៅនៃវិវាទ កម្ពុជា-ថៃ មុនឆ្នាំ២០០៦**

១. ដំណាក់កាលសម័យអាណាព្យាបាលបារាំង ..... ៨
១.១. មុនសម័យអាណាព្យាបាល ..... ៨
១.២. សម័យអាណាព្យាបាល ..... ៩
១.៣. ក្រោយសង្គ្រាមលោកលើកទី២ ..... ១៩
២. ដំណាក់កាលទីមួយនៃសង្គ្រាមត្រជាក់ ..... ១៩
២.១. ចលនាទាមទារឯករាជ្យរបស់ប្រទេសកម្ពុជាក្នុងសង្គ្រាមឥណ្ឌូចិន ..... ១៩
២.២. ទំនាក់ទំនង កម្ពុជា-ថៃ ក្នុងក្រសែភ្នែកសហរដ្ឋអាមេរិក ..... ២៤
២.៣. ទំនាក់ទំនង កម្ពុជា-ថៃ ក្នុងទិដ្ឋភាពនយោបាយអព្យាក្រឹត្យ របស់សម្តេចព្រះនរោត្តមសីហនុ ..... ៣០

២.៤. ស្ថានភាពប្រឈមមុខរវាង កម្ពុជា-ថៃ លើបញ្ហាប្រាសាទព្រះវិហារ
ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និង ១៩៦០........................................................ ៣៣
៣. ទំនាក់ទំនង កម្ពុជា-ថៃ ក្រោយរដ្ឋប្រហារឆ្នាំ ១៩៧០.................................... ៣៤
៣.១. សាធារណរដ្ឋខ្មែរ........................................................................ ៣៤
៣.២. កម្ពុជាប្រជាធិបតេយ្យ.................................................................... ៤០
៤.ទំនាក់ទំនង កម្ពុជា-ថៃ ក្នុងដំណាក់កាលចុងក្រោយនៃសង្គ្រាមត្រជាក់ (១៩៧៥-១៩៨៩).. ៤១
៤.១. ស្ថានភាពនយោបាយតំបន់.............................................................. ៤១
៤.២. សាធារណរដ្ឋប្រជាមានិតកម្ពុជា....................................................... ៤៥
៥. បំណុចចាប់ផ្តើមនៃដំណើរការស្វែងរកសន្តិភាពរបស់កម្ពុជា................................ ៤៩
៥.១. ការចរចាស្វែងរកសន្តិភាព............................................................... ៤៩
៥.១.១. ការប្រជែងកម្លាំងអន្តរជាតិនៅឆ្នាំ១៩៨៦.......................................... ៥០
៥.១.២. ជំនួបរវាងសម្តេចនរោត្តម សីហនុ និង លោក ហ៊ុន សែន
នៅហ្វែរអង់តារដឺន័រ ប្រទេសបារាំង លើកទី១.................................... ៥២
៥.១.៣. ដំណើរឆ្ពោះទៅការផ្សះផ្សានយោបាយភាគីខ្មែរទាំង៤............................ ៥៣
៥.១.៤. ជំនួបរវាងសម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន
នៅហ្វែរអង់តារដឺន័រ ប្រទេសបារាំង លើកទី២.................................... ៥៥
៥.១.៥. ភាពមិនចុះសម្រុងរវាងសម្តេចនរោត្តម សីហនុ និង GCKD ..................... ៥៦
៥.១.៦. ជំនួបក្រៅផ្លូវការរវាងភាគីខ្មែរទាំង៤ នៅបូហ្គ័រ នាខែកក្កដាឆ្នាំ១៩៨៨......... ៥៧
៥.២. ការប្រែប្រួលស្ថានភាពនយោបាយពិភពលោក........................................ ៦១
៥.៣. យុទ្ធសាស្ត្រនយោបាយទីក្រុងបាងកក ចំពោះអភិក្រមសន្តិភាពនៅកម្ពុជា.............. ៦៤
៦. ដំណាក់កាលក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣................................................ ៧២
៦.១. ឥរិយាបថនយោបាយមហាអំណាចលើបញ្ហាខ្មែរក្រហម................................. ៧២
៦.២. ឥរិយាបថនយោបាយថៃលើបញ្ហាខ្មែរក្រហម.......................................... ៧៥
៦.៣. ទស្សនៈនយោបាកម្ពុជាចំពោះ ទំនាក់ទំនងរវាង ថៃ
និង ចលនាចុងក្រោយរបស់ខ្មែរក្រហម.................................................. ៨១
៦.៤. ដង្ហើមសេដ្ឋកិច្ចខ្មែរក្រហម ជាមួយនឹងប្រទេសថៃ.................................... ៨៤

## ជំពូក ២
## វិវាទកម្ពុជា-ថៃ

១.មូលហេតុនៃវិវាទ......................................................................... ៩០
១.១. ឥទ្ធិពលនយោបាយផ្ទៃក្នុងថៃ.......................................................... ៩០
១.១.១. តួនាទីរាជាធិបតេយ្យថៃ នៅក្នុងសង្គមនយោបាយថៃ........................... ៩១
១.១.២.តួនាទីយោធាក្នុងសង្គមនយោបាយថៃ............................................. ១០៤
១.១.៣.តួនាទីរបស់លោក ថាក់ស៊ីន ស៊ីណាវ៉ាត់ ក្នុងសង្គមនយោបាយថៃ........... ១០៩

១.១.៤.ចលនាក្រុមអាវលឿង PAD..................................................................... ១១៣
១.១.៥.ចលនារបស់ រណសិរ្សប្រួបរួមដើម្បីប្រជាធិបតេយ្យប្រឆាំងនឹង
អំណាចផ្តាច់ការ(UDD)........................................................................ ១១៨
១.២. ឥទ្ធិពលនៃចរន្តជាតិនិយម........................................................................................ ១២៣
១.៣. មោទនភាពពូជសាសន៍ និង វប្បធម៌........................................................................... ១៣១
១.៤. ការសរសេរសៀវភៅប្រវត្តិសាស្ត្រ ........................................................................... ១៣៥
១.៤.១. សៀវភៅប្រវត្តិសាស្ត្រថៃ.................................................................................. ១៣៥
១.៤.២. សៀវភៅប្រវត្តិសាស្ត្រកម្ពុជា ............................................................................ ១៣៧
១.៥. ឥទ្ធិពលនៃចរន្តភូមិសាស្ត្រនយោបាយ........................................................................ ១៣៨
១.៥.១. វិវាទកម្ពុជា-ថៃ ក្នុង និង ក្រោយសង្គ្រាមត្រជាក់ ............................................... ១៣៨
១.៥.២. ឥទ្ធិពលនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយក្នុងតំបន់អាស៊ីអាគ្នេយ៍ ១៤០
២. ករណីប្រាសាទព្រះវិហារ............................................................................................. ១៥៤
២.១. ប្រវត្តិនៃការចូលកាន់កាប់ប្រាសាទព្រះវិហារពីសំណាក់ប្រទេសថៃ.........................១៥៥
២.២. ស្មារតីនៃការអនុវត្តសាលក្រមអន្តរជាតិ (ICJ) ឆ្នាំ១៩៦២ ...................................... ១៦១
២.៣. យុទ្ធសាស្ត្រថ្មីរបស់ប្រទេសថៃក្នុងការចូលកាន់កាប់ប្រាសាទព្រះវិហារ.................. ១៦៤
២.៤. ដំណើរការនៃការអនុវត្តសាលក្រមលើវិធានការបន្ទាន់របស់ ICJ.......................... ១៦៨
៣. បញ្ហាព្រំដែន កម្ពុជា-ថៃ........................................................................................... ១៧០
៣.១. បញ្ហាព្រំដែនគោក................................................................................................ ១៧០
៣.២. បញ្ហាព្រំដែន និង ការកេងចំណេញនយោបាយ......................................................... ១៧៣
៣.៣. បញ្ហាព្រំដែនសមុទ្រ និង ភាពមិនច្បាស់លាស់នៃតំបន់ត្រួតស៊ីគ្នា........................ ១៧៥

## ជំពូក ៣
## យន្តការនៃការដោះស្រាយវិវាទ

១. ដំណោះស្រាយទ្វេភាគី................................................................................................ ១៨៧
១.១. ទិដ្ឋភាពចាស់ និង ថ្មី នៃប្រក្រតីភាពទំនាក់ទំនងការទូត កម្ពុជា-ថៃ....................... ១៨៧
១.២. ជំនួបផ្លូវការ និង មិនផ្លូវការរវាងថ្នាក់ដឹកនាំប្រទេសទាំងពីរ................................. ១៩៤
១.៣. កិច្ចប្រជុំគណៈកម្មាធិការព្រំដែនរួមកម្ពុជា-ថៃ JBC............................................ ២០០
១.៤. កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ GBC......................................... ២០៣
១.៥. កិច្ចប្រជុំថ្នាក់ភូមិភាគកម្ពុជា-ថៃ RBC................................................................ ២០៩

២. ដំណោះស្រាយពហុភាគី............................................................................................. ២១០
២.១.យន្តការភាគីទី៣.................................................................................................. ២១០
២.២.យន្តការអាស៊ាន.................................................................................................. ២១៥
២.៣.យន្តការអង្គការសហប្រជាជាតិ.............................................................................២២៧
២.៤.យន្តការតុលាការយុត្តិធម៌អន្តរជាតិ ICJ............................................................... ២៤១

២.៥. ការចូលរួមរបស់ CAPDI........................................................................ ២៥៧
២.៦. គណៈកម្មការ ICC-Angkor...................................................................... ២៥៨
៣. យន្តការក្រៅផ្លូវការ.............................................................................................. ២៦០
៣.១. ទំនាក់ទំនងរវាងអង្គការក្រៅរដ្ឋាភិបាលកម្ពុជា និង អង្គការក្រៅរដ្ឋាភិបាលថៃ......... ២៦០
៣.២. ទំនាក់ទំនងអ្នកសារព័ត៌មានកម្ពុជា និង ថៃ.................................................. ២៦០
៣.៣. ចលនាមហាជនកម្ពុជាលើជម្លោះ កម្ពុជា-ថៃ.................................................. ២៦៤
៣.៤. ការខូតបាល់ទាត់............................................................................................ ២៦៨

សេចក្តីសន្និដ្ឋាន.................................................................................................. ២៧៣

គន្ថនិទ្ទេស............................................................................................................ ២៧៦

ឯកសារឧបសម្ព័ន្ធ.................................................................................................. ២៨៦

១-សេចក្តីប្រកាសរួម( Joint Communiqué )១៨ មិថុនា ២០០៨
២-លិខិតផ្លូវការ របស់លោក Samak Sundaravej នាយករដ្ឋមន្ត្រីថៃផ្ញើជូនសម្តេច ហ៊ុន សែន ថ្ងៃទី១៨ កក្កដា ២០០៨
៣-លិខិតផ្លូវការរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាផ្ញើជូនលោក Samak Sundaravej នាយករដ្ឋមន្ត្រីថៃ ១៩ កក្កដា ២០០៨
៤-ព្រះរាជក្រឹត្យតែងតាំងលោក ថាក់ស៊ីន ស៊ីណាវ៉ាត់
៥-លិខិតផ្លូវការរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាផ្ញើជូនលោកជំទាវ Maria Luiza Ribeiro Viotti, ប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ, ០៦ កុម្ភៈ ២០១១
៦-ផែនទីតំបន់គ្មានកងទ័ព (PDZ), ICJ, 18 JULY 2011
៧-សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា, ទាក់ទងនឹងសំណើរបស់កម្ពុជាសុំបកស្រាយសាលក្រម ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២, ១៨ កក្កដា ២០១១
៨-Thailand's Secret Unilateral Boundary Line & Map Showing the International Boundary and Thai Unilateral Lines at the Temple of Preah Vihear
៩-ផែនទីឧបសម្ព័ន្ធ១ ដែលICJ ទាញសំអាងចេញជីកាសម្រេចឆ្នាំ១៩៦២
១០-រូបថតបង្គោលសីមាព្រំដែនលេខ៣៤ ដែលអះអាងថា «ខុសទីតាំងដើម»

# ពាក្យប្រើជាអក្សរកាត់នៅក្នុងអត្ថបទ និង កំណត់សម្គាល់

- គ.ម២ គីឡូម៉ែត្រការេ
- -ដ- ដដែល
- ដ.ឯ.ម ដូចឯកសារមុន
- 3D ជាអក្សរកាត់នៃយុទ្ធសាស្ត្រគោលនយោបាយការទូតសហរដ្ឋអាមេរិកក្នុងអាណត្តិលោកបារ៉ាក់ អូបាម៉ា ដោយមានន័យថា «នយោបាយការទូត (Diplomacy) នយោបាយអភិវឌ្ឍ (Development) និង នយោបាយការពារជាតិ (Defence)»
- ADMM កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន ជាភាសាអង់គ្លេស ASEAN Defence Ministers' Meeting
- ARF វេទិកាសន្តិសុខតំបន់ ជាភាសាអង់គ្លេស Asean Regional Forum
- ASEAN (អាស៊ាន) សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ជាភាសាអង់គ្លេស Association of Southeast Asian Nations
- ASEM កិច្ចប្រជុំអាស៊ី-អឺរ៉ុប ជាភាសាអង់គ្លេស Asia-Europe Meeting
- ASC សហគមន៍សន្តិសុខអាស៊ាន ជាភាសាអង់គ្លេស ASEAN Security Community
- CAPDI ចលនាអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិអាស៊ីប៉ាស៊ីហ្វិក, ជាភាសាអង់គ្លេស Centrist Asia Pacific Democrats International
- CIA ទីភ្នាក់ងារស៊ើបការសម្ងាត់របស់សហរដ្ឋអាមេរិក, ជាភាសាអង់គ្លេស Central Intelligence Agency
- CIC គណៈកម្មការត្រួតពិនិត្យអន្តរជាតិ, ជាភាសាបារាំង Commission Internationale de Contrôle
- CMIM យន្តការពហុភាគីនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ, ជាភាសាអង់គ្លេស Chiang Mai Initiative Multilateralization
- DSMs យន្តការដោះស្រាយវិវាទ ជាភាសាអង់គ្លេស Dispute Settlement Mechanisms
- GCKD រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ជាភាសាអង់គ្លេស Coalition Government of Democratic Kampuchea
- GBC គណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ, ជាភាសាអង់គ្លេស Thai-Cambodia General Border Committee
- GIGA German Institute of Global and Area Studies, Institute of Asian Studies and Hamburg University Press
- Ibid ibdem (ដដែល)
- ICJ តុលាការយុត្តិធម៌អន្តរជាតិ ជាភាសាអង់គ្លេស International Court of Justice
- IRIC វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា ជាភាសាអង់គ្លេស International Relations Institute of Cambodia

- ISEAS វិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍ ជាភាសាអង់គ្លេស Institute of Southeast Asian Studies
- JBC គណៈកម្មាធិការចម្រុះខណ្ឌសីមាព្រំដែនកម្ពុជា-ថៃ ជាភាសាអង់គ្លេស Join Border Commission
- JIM ជំនួបក្រៅផ្លូវការនៅហ្សាកាតា (ហ្ស៊ីម) ជាភាសាអង់គ្លេស Jakarta Informal Meeting
- JWG ក្រុមការងាររួមកម្ពុជា-ថៃ, ជាភាសាអង់គ្លេស Join Working Group
- NBT ទូរទស្សន៍ជាតិថៃ ជាភាសាអង់គ្លេស National Broadcasting Service of Thailand
- nm Nautical Miles, 1nm=1.85200 kilometers
- OCM ទីស្តីការគណៈរដ្ឋមន្ត្រី
- Op. cit Opere citato (ដូចឯកសារមុន)
- PAD សម្ព័ន្ធភាពប្រជាជនដើម្បីប្រជាធិបតេយ្យ, ជាភាសាអង់គ្លេស The People's Alliance for Democracy, ជាភាសាថៃ พันธมิตรประชาชนเพื่อประชาธิปไตย
- PDZ តំបន់គ្មានកងទ័ព, ជាភាសាអង់គ្លេស Provisional Demilitarized Zone
- PPP គណបក្សអំណាចប្រជាជន, ជាភាសាអង់គ្លេស People Power Party
- SEATO សន្ធិសញ្ញាអង្គការអាស៊ីអាគ្នេយ៍, ជាភាសាអង់គ្លេស Southeast Asia Treaty Organization
- SNC ឧត្តមក្រុមប្រឹក្សាជាតិ
- TAC សន្ធិសញ្ញាមិត្តភាព និង សហប្រតិបត្តិការតំបន់អាស៊ីអាគ្នេយ៍, ជាភាសាអង់គ្លេស Treaty of Amity and Cooperation in Southeast Asia
- TOR លក្ខខណ្ឌប្រតិបត្តិ, ជាភាសាអង់គ្លេស Term of Reference
- TRT Thai Rak Thai
- UDD រណសិរ្សរួបរួមដើម្បីប្រជាធិបតេយ្យប្រឆាំងនឹងអំណាចផ្តាច់ការ, ជាភាសាអង់គ្លេស The United Front for Democracy Against Dictatorship, ជាភាសាថៃ แนวร่วมประชาธิปไตยต่อต้านเผด็จการแห่งชาติ; นปช
- UNSC ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជាភាសាអង់គ្លេស United Nations Security Council
- UNTAC អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា ជាភាសាអង់គ្លេស United Nations Transitional Authority in Cambodia

# មូលន័យសង្ខេប

ក្រោយរដ្ឋប្រហារទម្លាក់លោក ថាក់ស៊ីន ស៊ីណាវ៉ាត់ ពីនាយករដ្ឋមន្ត្រីប្រទេសថៃ បានរុញច្រានសភាពការណ៍នយោបាយប្រទេសនេះធ្លាក់ទៅក្នុងជម្លោះផ្ទៃក្នុងកាន់តែធ្ងន់ធ្ងរថែមទៀត។ ក្រុមអ្នកនយោបាយឱកាសនិយមថៃ បានផ្ទេរជម្លោះនយោបាយផ្ទៃក្នុងនេះ លើប្រទេសជិតខាង ដោយប្រើប្រាស់បញ្ហាជាតិនិយមទឹកដី។ ការសិក្សាពី «វិវាទ កម្ពុជា-ថៃ (២០០៦-២០១២)» មានគោលបំណងសំខាន់ស្វែងរកដើមចម ដែលនាំឲ្យមានជម្លោះលើសពីមូលហេតុជាតិនិយមដែលលើកខាងដើម និងព្រមជាមួយនឹងការសិក្សាពីយន្តការគន្លឹះដែលរដ្ឋភាគីទាំងពីរបានប្រើប្រាស់សម្រាប់ដោះស្រាយ។

ដើម្បីបំពេញស្នាដៃនិក្ខេបបទនេះឱ្យពេញគ្រប់ជ្រុងជ្រោយ យើងខ្ញុំនឹងធ្វើការសិក្សាជាបីជំពូក ដែលក្នុងនោះមាន ៖ ជំពូក១).សិក្សាពីទិដ្ឋភាពទូទៅនៃវិវាទ កម្ពុជា-ថៃ មុនឆ្នាំ២០០៦។ ជំពូក២). សិក្សាពីវិវាទកម្ពុជា-ថៃ ដែលនឹងបកស្រាយពីបច្ចុប្បន្នភាពនៃជម្លោះ និង មូលហេតុនាំទៅរកជម្លោះ និង ជំពូក៣). សិក្សាវាយតម្លៃលើយន្តការដែលភាគីជម្លោះទាំងពីរបានប្រើប្រាស់កន្លងមក។

រីឯសេចក្តីសន្និដ្ឋាន យើងខ្ញុំនឹងបកស្រាយពីមូលហេតុពិតប្រាកដ ដែលតែងនាំឱ្យប្រទេសទាំងពីរមានជម្លោះនឹងគ្នា ព្រមជាមួយនឹងការស្វែងរកយុទ្ធសាស្ត្រគន្លឹះ ដែលអាចនាំទៅរកដំណោះស្រាយជាអចិន្ត្រៃយ៍បាន។

# Abstract

The coup d'état against former Thai Prime Minister Thaksin Shinawatra escalated the internal conflict within Thailand political situation. Thai opportunist politicians then changed this conflict from being internal into being transnational against its neighboring countries by using the issue of territorial nationalism as a tool. A study on "Cambodian-Thai Conflict (2006-2012)" aimed principally at finding out the root cause(s) of the conflict, besides the reason of nationalism, and studying key solution mechanisms the two state parties deployed.

In order to write up a comprehensive thesis, I categorize my study into three chapters: Chapter 1 lays out the overview of Cambodian-Thai conflict before 2006. Chapter 2 studies the Cambodian-Thai Conflict, explaining the current state of the conflict and its causes. And Chapter 3, finally, evaluates the mechanisms used by both parties in resolving the conflict.

In the conclusion section, I will discuss the actual reasons that led to the conflict between the two countries, and I will propose key strategies that can provide permanent solutions to the conflict.

# សង្ខេបនិក្ខេបបទ

រលកនយោបាយប្រទេសទាំងពីរ ជាពិសេសប្រទេសថៃនាទសវត្សរ៍ថ្មីនេះ បានធ្វើឱ្យអវិភាព នៃទំនាក់ទំនងទ្វេភាគី កម្ពុជា-ថៃ ធ្លាក់ចុះក្នុងសភាពធ្ងន់ធ្ងរកាន់តែខ្លាំង។ ចរន្តជាតិនិយមថៃ បច្ចុប្បន្ន ត្រូវបានអ្នកនយោបាយថៃ អភិជនបាងកក និង ក្រុមបញ្ញវន្តអភិរក្សជ្រុលនិយមយកមកប្រើប្រាស់ក្នុង ការបំភ្លៃប្រវត្តិសាស្ត្រ ដើម្បីលើកតម្កើងជនជាតិខ្លួន។ ជាមួយគ្នានោះគេបានប្រើប្រាស់បញ្ហាប្រាសាទ ព្រះវិហារ ដើម្បីចិញ្ចឹមចលនាជាតិនិយមបម្រើផលប្រយោជន៍នយោបាយផ្ទៃក្នុងថៃ។ លើសពីនោះ ទៀត គេប្រើប្រាស់បញ្ហាជាតិនិយមក្នុងបំណងបំភាន់ភ្នែកមហាជនខ្លួនឯង ដើម្បីទាញសមាណចិត្ត អ្នកគាំទ្រសកម្មភាពនយោបាយ។ ក្នុងន័យនេះ យើងយល់បានថា ប្រសិនបើអ្នកនយោបាយថៃមិន ប្រកាន់នូវគំនិតអភិរក្សនិយមជ្រុល ហើយងាកមកទទួលស្គាល់តាមសច្ចភាពប្រវត្តិសាស្ត្រពិតនោះ ប្រទេសទាំងពីរ កម្ពុជា-ថៃ នឹងមិនមានអវិភាពច្រើនយ៉ាងនេះនោះទេ។

**ជំពូក១៖** ការសិក្សាប្រវត្តិសាស្ត្រ បានបង្ហាញឱ្យឃើញថា ប្រទេសថៃតែងកេងចំណេញលើ ទំនាក់ទំនងទ្វេភាគី កម្ពុជា-ថៃ ជាដរាបរៀងមក ពោលគឺចាប់តាំងពីមុនសម័យអាណានិគមមកម្ល៉េះ ជាពិសេស នៅពេលដែលប្រទេសកម្ពុជាចុះទន់ខ្សោយ ថៃឆ្លៀតឱកាសអនុវត្តនយោបាយពង្រីកទឹក ដីរបស់ខ្លួន។ ក្នុងសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥) ឆ្លៀតឱកាសដែលប្រទេសបារាំង ចុះខ្សោយប្រទេសថៃបានចុះហត្ថលេខាសម្ព័ន្ធភាពជាមួយនឹងជប៉ុន ហើយបានទាមទារទឹកដី ដែល អះអាងថាបាត់បង់ពីមុនទៅឱ្យខ្លួនកាន់កាប់វិញ។ សង្គ្រាម បារាំង-ថៃ បានប្រព្រឹត្តទៅនៅចន្លោះ ខែតុលា ឆ្នាំ១៩៤០ និង ថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៤១។ ដោយមានអន្តរាគមន៍ពីជប៉ុន សង្គ្រាមត្រូវ បានបញ្ចប់នៅក្នុងខែឧសភា ហើយទាហានថៃបានចូលមកក្នុងទឹកដីនៃប្រទេសកម្ពុជា។ នៅពេលនោះ រដ្ឋាភិបាលយោធាថៃ ដែលដឹកនាំដោយ ភិបុនសង្គ្រាម បានបដិសេធយ៉ាងដាច់ខាតចំពោះទឹកដីភាគ ពាយ័ព្យជារបស់ប្រទេសកម្ពុជា គឺចាត់ទុកទឹកដីនេះជារបស់ថៃ។

ជម្លោះអធិបតេយ្យ បង្កើតទៅជាបញ្ហាស្មុគស្មាញមួយរវាងសៀម និង មហាអំណាចអាណា និគម ជាពិសេសគឺបារាំង ហេតុនេះហើយបានជាយើងឃើញមានសន្ធិសញ្ញា អនុសញ្ញា និង កិច្ចព្រម ព្រៀង ជាច្រើនដូចជា សន្ធិសញ្ញាបារាំង-សៀម ១៨៦៧, សន្ធិសញ្ញាបារាំង-សៀម ១៨៩៣, ១៩០៤, និង ១៩០៧ អនុសញ្ញាបារាំង-ថៃ ថ្ងៃទី៩ ឧសភា ១៩៤១ និង កិច្ចព្រមព្រៀងបារាំង-សៀម ថ្ងៃទី១៧ វិច្ឆិកា ១៩៤៦ ជាដើម។ ប្រទេសថៃបានបង្កើតឡើងនូវចលនាជាតិនិយមជាច្រើនដើម្បីប្រឆាំងពួក អាណានិគម ហើយការប្រឆាំងនេះគេសង្ឃឹមថានឹងអាចទាមទារទឹកដីដែលគេបានអះអាងថាបាត់បង់ នោះចូលទៅក្នុងដែនដីរបស់សៀមវិញ។

នៅក្នុងចន្លោះឆ្នាំ១៩៤៦ទៅ១៩៤៩ រដ្ឋាភិបាលថៃបានអនុញ្ញាតឱ្យខ្មែរកុម្មុយនីស្ត (ឥស្សរៈ កុម្មុយនីស្ត)ក៏ដូចជាពួកខ្មែរឥស្សរៈសេរី (ស្តាំនិយម) ទិញសព្វាវុធដោយឆ្លងកាត់ទឹកដីថៃ។ ឥរិយាបថ នយោបាយថៃ លើចលនាខ្មែរឥស្សរៈទាំងពីរ ដែលមាននិន្នាការនយោបាយខុសគ្នា ជំរុញឱ្យធ្វើចលនា បណ្តេញអាណានិគមបារាំងចេញពីកម្ពុជា ដើម្បីផ្តល់ឱកាសដល់ប្រទេសថៃបានតាំងខ្លួនជាអ្នកចាត់ ចែងជោគវាសនាកម្ពុជាតទៅទៀត។ ម្យ៉ាងទៀត ប្រទេសថៃតែងយល់ឃើញ ដូចដែលបារាំងបានលើក

ឡើងដែរថា ប្រទេសកម្ពុជានឹងចុះខ្សោយខ្លាំងជាមិនខាននៅពេលដែលអាណានិគមបារាំងប្រគល់ឯករាជ្យមកឱ្យកម្ពុជានោះ។ ជាងនេះទៅទៀត ថៃយល់ថា មនោគមន៍វិជ្ជានយោបាយនៃចលនានេះមិនមែនប្រឆាំងតែបារាំងទេ ប៉ុន្តែប្រឆាំងខ្មែរគ្នាឯងទៀតផង។ ប្រទេសថៃក៏អាចប្រើប្រាស់ពួកគេដើម្បីដណ្តើមមកវិញនូវទឹកដីមួយចំនួនដែលថៃអះអាងថាបាត់បង់ដោយសារបារាំងនោះ។ ពាក់ព័ន្ធនឹងបញ្ហាជៀតជ្រែករបស់ប្រទេសថៃសម័យកាលនេះ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានថ្លែងនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ថា «...ពីមុនស្តេចខ្មែរបានពាក់មកុដចេញពីបាងកក...»។ មានការកត់សម្គាល់ឃើញថា នៅឆ្នាំ១៩៤៩ បើទោះបីជាបារាំងប្រគល់ឯករាជ្យឱ្យខ្មែរមិនទាន់ពេញលេញក៏ដោយ ក៏សហរដ្ឋអាមេរិក បានទទួលស្គាល់ឯករាជ្យខ្មែរក្នុងថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៥០ ដូចគ្នានឹងប្រទេសថៃបានប្រកាសទទួលស្គាល់ឯករាជ្យនៃប្រទេសកម្ពុជា ហើយបានមកដាក់ទូតនៅកម្ពុជា នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៥០។

បើយើងពិនិត្យមើលបញ្ហាខាងលើនេះ ថៃមាននយោបាយស្របគ្នាជាមួយសហរដ្ឋអាមេរិក។ ប៉ុន្តែអ្វីដែលខុសគ្នាគឺ សហរដ្ឋអាមេរិកដាក់ទូតនៅកម្ពុជា ក្នុងគោលបំណងប្រឆាំងរបបអាណានិគមចាស់ៗដូចជាបារាំង និង អង់គ្លេស ក៏ដូចជាការទប់ស្កាត់ការរីករាលដាលលទ្ធិកុម្មុយនីស្តនៅក្នុងតំបន់ឥណ្ឌូចិន។ រីឯថៃប្រញាប់ប្រញាល់គាំទ្រដោយសារមានបំណងចង់ឱ្យបារាំងចេញពីកម្ពុជាឱ្យបានឆាប់រហ័ស ព្រោះបារាំងធ្លាប់ដេញថៃចេញពីតំបន់នេះតាំងពីឆ្នាំ១៨៦៧ ហើយគេនឹងមានប្រៀបឈ្នះលើប្រទេសកម្ពុជា ពីព្រោះកម្ពុជាមានកម្លាំងទ័ព និង សេដ្ឋកិច្ចទន់ខ្សោយ។

ជារួម យើងឆ្លើយនឹងគន្លឹះបញ្ហានៅក្នុងចំណុចដែលចោទថា «ហេតុអ្វីប្រទេសថៃប្រញាប់ប្រញាល់ប្រកាសទទួលស្គាល់ឯករាជ្យនៃប្រទេសកម្ពុជា ហើយបានមកដាក់ទូតនៅកម្ពុជា នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៥០ មុនអាណានិគមបារាំងប្រគល់អោយទៅទៀត?» គឺថៃចង់ឃើញប្រទេសកម្ពុជាផុតពីដៃមហាអំណាច និង ធ្លាក់ចុះខ្សោយ។

ក្នុងរបបសាធារណៈរដ្ឋខ្មែរ ថ្វីត្បិតប្រទេសកម្ពុជាបានងាកទៅភ្ជាប់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ដែលជាមហាអំណាច មានសម្ព័ន្ធភាពយុទ្ធសាស្ត្រជាមួយប្រទេសថៃ ក៏យើងសង្កេតឃើញថា ទំនាក់ទំនង កម្ពុជា-ថៃ មិនអាចឈានទៅរកប្រក្រតីភាពបានដែរ។ ប្រទេសថៃបានមើលឃើញពីភាពមិនចុះសម្រុងផ្ទៃក្នុងនៃសាធារណរដ្ឋខ្មែរ ថាមិនអាចធ្វើឱ្យប្រទេសនេះរឹងមាំបាន។ ជាងនេះទៅទៀត ថៃធ្លាប់បានជ្រោមជ្រែងចលនាខ្មែរឥស្សរៈ ក្នុងរូបភាពបណ្តេញកុម្មុយនីស្ត និង ជួយជ្រោមជ្រែងបណ្តេញអាណានិគម ប៉ុន្តែការពិតគឺក្នុងបំណងចិញ្ចឹមជម្លោះផ្ទៃក្នុងខ្មែរទៅវិញទេ។

នាទសវត្សឆ្នាំ១៩៨០ នៅក្នុងក្របខ័ណ្ឌនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ប្រទេសថៃមិនត្រឹមតែមិនបានជួយពន្លត់ភ្លើងសង្គ្រាមផ្ទៃក្នុងប្រទេសកម្ពុជាក្នុងនាមជាប្រទេសជិតខាងប៉ុណ្ណោះទេ ថៃមទាំងបានលោតចូលក្នុងឆាកនយោបាយចិនក្នុងការធ្វើសង្គ្រាមប្រឆាំងជាមួយកម្ពុជា និង ឥណ្ឌូចិន ក្នុងខណៈពេលបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់នេះ ជាពិសេសឥណ្ឌូនេស៊ី បានចាត់ទុកចិនជាគ្រោះថ្នាក់ដល់អាស៊ាន។ នៅពេលដែលថៃ និង ចិន ពិភាក្សាគ្នាអំពីការកសាងឃ្លាំងផ្ទុកអាវុធរបស់ចិន នៅប្រទេសថៃ បណ្តាប្រទេសក្នុងសមាគមអាស៊ាន សុទ្ធតែមានការព្រួយបារម្ភក្នុងកម្រិតខុសគ្នា។ នៅក្នុងទសកាលនេះ យើងអាចមើលឃើញទៀតថា បើទោះជាប្រទេសថៃមិនពេញចិត្តនឹងសម្តេចព្រះនរោត្តម សីហនុ យ៉ាងខ្លាំងក្នុងបញ្ហាព្រះវិហារ និង ខេត្តមួយចំនួន ដែលថៃបង្ខំចិត្តប្រគល់ឱ្យកម្ពុជា

ក្រោយសង្គ្រាមលោកលើកទី២ តែប្រទេសថៃ នៅតែគាំទ្រចំពោះសម្តេចនរោត្តមសីហនុ ប្រឆាំងនឹងរដ្ឋាភិបាលក្រុងភ្នំពេញ ក្នុងបំណងចំណេញយុទ្ធភូមិសាស្ត្រនយោបាយរបស់ខ្លួន និង ការកេងចំណេញផលប្រយោជន៍សេដ្ឋកិច្ច ដែលប្រទេសនេះបានរកស៊ីជាមួយភាគីប្រឆាំងរដ្ឋាភិបាលភ្នំពេញនាពេលនោះ។ ជាយុទ្ធសាស្ត្ររបស់ថៃ ប្រទេសនេះពុំអនុញ្ញាតឱ្យសម្តេចព្រះនរោត្តម សីហនុ មានកម្លាំងគ្រប់គ្រាន់ ដើម្បីត្រួតត្រាអំណាចឡើយ។ សម្តេចព្រះនរោត្តម សីហនុ បានទទួលស្គាល់ថា «*ប្រៀបធៀបបញ្ជីដែលចិនបានផ្តល់ជំនួយសម្រាប់កងទ័ពរបស់ខ្ញុំ (សម្តេចព្រះនរោត្តមសីហនុ) ខ្ញុំបានទទួលតែ ១០%គត់ពីថៃ*» ព្រះអង្គបានបន្តទៀតថា «*ថៃមិនចង់ឱ្យសីហនុ ខ្លាំងទេ គេចង់ឱ្យខ្មែរក្រហមគ្របសង្កត់រដ្ឋាភិបាលចម្រុះ ថៃស្អប់សីហនុ ថៃមិនចង់បានសីហនុទេ*»។

បើយើងពិនិត្យមើលនៅក្នុងដំណាក់កាលចុងក្រោយនៃចលនាខ្មែរក្រហម ចុងទសវត្សឆ្នាំ ១៩៩០ (1990s) បានបង្ហាញថា ភាពរឹងមាំ និង ចុះខ្សោយរហូតដល់ដួលរលំទាំងស្រុងរបស់ចលនាខ្មែរក្រហម មានការជាប់ពាក់ព័ន្ធនឹងប្រទេសថៃដោយមិនអាចប្រកែកបាន។ ដង្ហើមសេដ្ឋកិច្ចរបស់តាម៉ុក នៅអន្លង់វែង មានទំនាក់ទំនងជាមួយប្រទេសថៃតែមួយប៉ុណ្ណោះ។ ប្រទេសថៃតែងប្រកាន់គោលជំហរមិននៅកៀកនឹងនិន្នាការកុម្មុយនីស្ត ក៏ប៉ុន្តែយើងចោទសួរវិញថា ទំនាក់ទំនងជិតដិតជាមួយចលនាខ្មែរក្រហមស្ថិតនៅក្នុងគោលការណ៍ណាមួយ? ជាគោលការណ៍ផលប្រយោជន៍សេដ្ឋកិច្ចប្រទេសថៃសុទ្ធសាធ ឬ ជាគោលការណ៍ផលប្រយោជន៍សេដ្ឋកិច្ចប្រទេសថៃ រួមនឹងការកេកូរកកាយផ្ទៃក្នុងកម្ពុជា?

ទឡ្ហីករណ៍បញ្ជាក់ហេតុផលនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន សម្តេច ហ៊ុន សែន បានលើកឡើងជារឿយៗ នៅអំឡុងពេលសភាពការណ៍ព្រំដែនតានតឹងខ្លាំងក្នុងចន្លោះឆ្នាំ២០០៨ ដល់ឆ្នាំ២០១១ ក្នុងសេចក្តីថា «...*ប្រទេសថៃតែងបានពាក់ព័ន្ធនឹងនយោបាយផ្ទៃក្នុងកម្ពុជានាទសវត្សឆ្នាំ១៩៨០ និង ១៩៩០លើករណីខ្មែរក្រហមនេះ*...»។ លើសពីនោះទៀតនៅក្នុងដំណើរការចរចាស្វែងរកសន្តិភាពឆ្ពោះទៅរកកិច្ចព្រមព្រៀងប៉ារីស សម្តេច ហ៊ុន សែន បានលើកឡើងពីតួនាទីថៃ ក្នុងការបញ្ចុះបញ្ចូលត្រីភាគី ដើម្បីទទួលយកនូវគំនិតស្តីពីការបង្កើតក្រុមប្រឹក្សាបង្រួបបង្រួមជាតិ ក៏ដូចជាការបង្កកទំនាក់ទំនងរវាងថៃ និង ខ្មែរក្រហម។

ជារួម ប្រវត្តិវិវាទ កម្ពុជា-ថៃ មុនឆ្នាំ២០០៦ បានបង្ហាញពីភាពមិនប្រាជកប្រជានៅក្នុងទំនាក់ទំនងនៃប្រទេសទាំងពីរ។ នៅក្នុងដំណើរវិវត្តនយោបាយកម្ពុជាមុននិងក្រោយសម័យអាណាគមប្រទេសកម្ពុជាទទួលរងនូវការរំលោភបំពានពីសំណាក់ប្រទេសថៃជាច្រើនករណី ដែលធ្វើឱ្យមានវិវាទបន្តបន្ទាប់ ដូចមានការបកស្រាយនៅក្នុងជំពូក២ខាងក្រោម។

**ជំពូក២៖** ភាពមិនច្បាស់លាស់ក្នុងប្រព័ន្ធនយោបាយដឹកនាំរដ្ឋនៃប្រទេសថៃបានធ្វើឱ្យអំណាចនីតិប្រតិបត្តិនៃប្រទេសនេះ មិនមានស្ថិរភាព ព្រមទាំងបាត់បង់តុល្យភាពអំណាច។ ក្នុងនោះយើងសង្កេតឃើញថា រដ្ឋាភិបាលថៃមិនមានសិទ្ធលើកងទ័ព ជាឧទាហរណ៍នាឆ្នាំ២០០៨ ទ័ពថៃចូលមកតំបន់ប្រាសាទព្រះវិហារ នៅពេលភាគីកម្ពុជាស្នើឱ្យដកទៅវិញ ថៃឆ្លើយថាចាំសួរសភាសិន។ នៅដើមអាណត្តិនយោបាយរបស់លោកស្រី យីងឡាក់ ស៊ីណាវ៉ាត់ អតីតនាយករដ្ឋមន្ត្រីថៃ លោក ថាក់ស៊ីន ស៊ីណាវ៉ាត់ បានសម្តែងការព្រួយបារម្ភពីជម្លោះក្នុងចំណោមពលរដ្ឋថៃនឹងកាន់តែរីករាលដាលក្តៅគគុក

ឡើងវិញជាក់ជាមិនខាន ប្រសិនបើ ICJ នឹងបកស្រាយ ដូចសាលដីកា ១៥ មិថុនា ១៩៦២ ដែលកាត់សេចក្តីឱ្យភាគីថៃចាញ់ក្តីក្នុងករណីប្រាសាទព្រះវិហារនោះ។

អំណាចរាជវាំង និង ច្បាប់ប្រមាថព្រះចេស្តា (lèse majesté laws) ក៏ជាករណីមួយសម្រាប់តុល្យភាពនយោបាយថៃផងដែរ។ អំណាចនេះត្រូវបានអ្នកវិភាគបស្ចិមប្រទេសវាយតម្លៃថា «អំណាចព្រះមហាក្សត្រ លើសរដ្ឋធម្មនុញ្ញដែលបានចែង» និង ឱ្យតម្លៃថា ព្រះមហាក្សត្រថៃ គឺជាស្ថាប័នថ្មីមួយ ដ៏មានឥទ្ធិពលលើនយោបាយ ដែលគេអាចហៅថា «រាជាធិបតេយ្យអាស្រ័យបណ្តាញ»។ ដោយមើលឃើញពីឥទ្ធិពលបណ្តាញនយោបាយនេះ លោក ថាក់ ស៊ីនស៊ីណាវ៉ាត់ នាយករដ្ឋមន្ត្រីថៃ ដែលបានជាប់ឆ្នោតចំនួនពីរដងនៅក្នុងឆ្នាំ២០០១ និង ឆ្នាំ២០០៥ ធ្លាប់ធ្វើនយោបាយផ្លាស់ប្តូរបណ្តាញនៃអំណាចរាជវាំង ដោយដាក់ជំនួសវិញនូវបណ្តាញថ្មី ដែលជាហេតុផលមួយក្នុងចំណោមហេតុផ្សេងទៀតក្នុងការផ្តល់ឱកាសឱ្យក្រុមយោធាធ្វើរដ្ឋប្រហារថ្ងៃ១៩ ខែកញ្ញា ឆ្នាំ២០០៦។

តាមរយៈកំណត់ហេតុសម្ងាត់ការទូតសហរដ្ឋអាមេរិក ដែលបានចុះផ្សាយដោយគេហទំព័រ Wikileaks និង បានយកមកផ្សាយបន្តដោយកាសែតអង់គ្លេស The Guardian អតីតនាយករដ្ឋមន្ត្រីថៃ សាម៉ាក់ ស៊ុនដារាវ៉េច បាននិយាយថា ព្រះអគ្គមហេសីរបស់ ភូមិពុល ជាបុគ្គលសំខាន់ដែលនាំឱ្យមានរដ្ឋប្រហារឆ្នាំ២០០៦ និង ទម្លាក់លោក ថាក់ស៊ីន ចេញពីតំណែងនាយករដ្ឋមន្ត្រី។ បើតាមកាសែតអង់គ្លេស The Guardian ដែលបានដកស្រង់ចំណុចខ្លះនៃកំណត់ទូតអាមេរិក មកចុះផ្សាយបន្តទៀតនោះ អតីតនាយករដ្ឋមន្ត្រីថៃលោក សាម៉ាក់ ស៊ុនដារាវ៉េច បានជួបនិយាយគ្នាជាមួយមន្ត្រីទូតអាមេរិកប្រចាំក្រុងបាងកក នៅខែតុលា ឆ្នាំ២០០៨ ពោលគឺមួយខែក្រោយពេលដែលលោក សាម៉ាក់ បានលាលែងចេញពីប្រធានបក្ស និង បញ្ចប់តួនាទីជានាយករដ្ឋមន្ត្រីថៃ។ លោកបាននិយាយប្រាប់មន្ត្រីទូតអាមេរិកថា លោកជឿថា ព្រះរាជិនី ស៊ីរីគីត ជាអ្នកជម្រុញឱ្យមានរដ្ឋប្រហារទម្លាក់លោកនាយករដ្ឋមន្ត្រី ថាក់ស៊ីន ស៊ីណាវ៉ាត់ ចេញពីមុខតំណែង។

រីឯក្រុមយោធាថៃក៏បានជាប់ពាក់ព័ន្ធនឹងរដ្ឋប្រហារឆ្នាំ២០០៦ ផ្អែកលើផលប្រយោជសេដ្ឋកិច្ច និង សង្គមនយោបាយថៃ។ ត្រង់ន័យនេះ យើងអាចមើលឃើញថា អភិក្រមនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចលោក ថាក់ស៊ីន ពិតជាប៉ះពាល់ផលប្រយោជន៍ក្រុមយោធា ព្រោះក្រុមនេះសុទ្ធតែជាមនុស្សដែលកាន់កាប់សហគ្រាសធំៗជាច្រើននៅក្នុងប្រទេសថៃ លើសពីនេះទៀត រដ្ឋប្រហារឆ្នាំ២០០៦ បានផ្តល់ឱ្យពួកគេនូវការពង្រីកឥទ្ធិពលបន្ថែមលើនយោបាយផ្ទៃក្នុង ព្រមទាំងពង្រីកខ្ទង់ចំណាយយោធាផងដែរ។

*«គិតថ្មី សកម្មភាពថ្មី»* ជាបាវចនា របស់ TRT ដែលលោកថាក់ស៊ីន តែងថ្លែងប្រាប់មហាជនថា *«ខ្ញុំនេះហើយជាអ្នកនយោបាយ ដែលមានបំណងពិតប្រាកដក្នុងការស្រោចស្រង់ជាតិឱ្យផុតពីវិបត្តិដ៏សែនធ្ងន់ធ្ងរនៅឆ្នាំ១៩៩៧»*។ តាមរយៈគោលនយោបាយ Pro-Poor Policies បានជម្រុញឱ្យប្រជាប្រិយភាពរបស់លោក ថាក់ស៊ីន កាន់តែជ្រួតជ្រាបដល់ស្រទាប់វណ្ណៈកសិករ និង អ្នកក្រីក្រទូទាំងប្រទេស ដែលអាចវាយតម្លៃបានថា ជាប្រភពការធ្វើរដ្ឋប្រហារយោធាទម្លាក់លោក ថាក់ស៊ីន ស៊ីណាវ៉ាត់ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦។ ប្រជាប្រិយភាពរបស់លោក ថាក់ស៊ីន ក្នុងទសវត្សចុងក្រោយនេះ បានឈានទៅប្រៀបផ្ទឹមនឹងព្រះមហាក្សត្រ ដែលជាបុព្វហេតុនាំឱ្យមានចលនាប្រឆាំងនឹងរូបលោក

លើករណីផ្សេងៗជាច្រើន។ ចលនាប្រឆាំងនេះ ដឹកនាំដោយសម្ព័ន្ធប្រជាជនដើម្បីប្រជាធិបតេយ្យ ឬ «ចលនាក្រុមអាវលឿង PAD»។

ក្នុងន័យនេះ អាចទាញសន្និដ្ឋានថា មិនចំពោះតែរដ្ឋាភិបាលរបស់លោកស្រី យីងឡាក់ នោះទេ ប៉ុន្តែសម្រាប់នយោបាយប្រទេសថៃទាំងមូល ពិតជាពិបាកនឹងនិយាយអំពីស្ថិរភាពណាស់ ដរាបណាបណ្តាញរាជវាំងរួមមាន ក្រុមអាមាត្យ និង យោធា នៅតែមានអំណាចខ្លាំង។

ចលនាក្រុមអាវលឿង PAD បង្កើតឡើងក្នុងគោលបំណងប្រឆាំងនឹងលោក ថាក់ស៊ីន និង សម្ព័ន្ធរបស់លោក។ PAD បានចាប់ផ្តើមក្នុងចលនា នៅក្នុងវិបត្តិនយោបាយថៃឆ្នាំ២០០៥-២០០៦ និង ២០០៨ រួមទាំងបញ្ហាព្រំដែនកម្ពុជា និង ថៃផងដែរ។ សមាជិកសំខាន់ៗរបស់ក្រុមនេះ គឺប្រមូលផ្តុំអ្នករាជានិយមថៃ ក្រុមអ្នកជំនួញថ្នាក់ខ្ពស់ និង ថ្នាក់កណ្តាលនៅបាងកក (ដែលគេហៅថាគហិបតីបាងកក) ក្រុមបញ្ញវន្តអភិរក្សនិយម និង ភូមិភាគខាងត្បូងថៃ ដែលទទួលបានការគាំទ្រពីក្រុមយោធាថៃ និង ថ្នាក់ដឹកនាំគណៈបក្សប្រជាធិបតេយ្យ។ នៅក្នុងសកម្មភាពតវ៉ា ពួកគេបានអំពាវនាវឱ្យយោធា និងក្រុមឥស្សរជនអភិរក្សនិយម ចូលកាន់កាប់អំណាចនយោបាយសំខាន់ៗ។ លើសពីនេះ ចលនានេះបញ្ឆេះកំហឹងរាលដាលប្រឆាំងដល់ប្រទេសកម្ពុជា រហូតដល់រដ្ឋមន្ត្រីការបរទេសថៃ ដែលជាអ្នកដឹកនាំសំខាន់របស់ PAD បានប្រើភាសាមិនគប្បីដល់នាយករដ្ឋមន្ត្រីកម្ពុជាថា «អ្នកលេង» ព្រមទាំងប្រមាថថា «នឹងយកឈាមហ៊ុនសែនមកលាងជើង»ខ្លួនទៀតផង។

គួរបញ្ជាក់ថា ទស្សនៈជាតិនិយមរបស់ PAD បានពិពណ៌នាខ្លួនឯងថា ជាអ្នកជាតិនិយម ហើយប្រកាសប្រឆាំងជាដាច់ខាតចំពោះជនណា ឬ បក្សណាដែលធ្វើឱ្យប៉ះពាល់ដល់បូរណភាពទឹកដីថៃ។ ផ្តើមចេញពីចន្លេនេះ PAD បានប្រឆាំងនឹងរដ្ឋបាល សាម៉ាក់ ដែលបានគាំទ្រដល់ការចុះបញ្ជីប្រាសាទព្រះវិហារជាសម្បត្តិបេតិកភ័ណ្ឌពិភពលោក ក្នុងខណៈដែលពួកគេនៅតែចាត់ទុកថាដី ៤.៦គ.ម² ជុំវិញប្រាសាទនោះជាកម្មសិទ្ធិរបស់ថៃ។ PAD បានចោទប្រកាន់ថា ពួកគេបានអំពាវនាវ ប្រជាជន PPP ក្នុងលក្ខខណ្ឌថាលោក ថាក់ស៊ីន បានផ្តល់ផលប្រយោជន៍ដល់ប្រទេសកម្ពុជា ក្នុងគម្រោងអភិវឌ្ឍន៍ទីក្រុងទំនើបនៅខេត្តកោះកុងនៃប្រទេសកម្ពុជា។ លើសពីនោះទៀត ពួកគេបានអំពាវនាវដល់វិនិយោគិនថៃនៅកម្ពុជាឱ្យវិលត្រលប់ទៅវិញ ឱ្យបិទច្រកព្រំដែនទាំងអស់ជាមួយកម្ពុជា បញ្ឈប់ជើងហោះហើរទាំងពីភ្នំពេញ និង សៀមរាប ជាមួយបាងកក ព្រមទាំងអំពាវនាវបញ្ឈប់សកម្មភាពរបស់គណៈកម្មការដែនទឹកសមុទ្រត្រួតស៊ីគ្នា។

ចន្លេជាតិនិយមថៃ នៅពេលបច្ចុប្បន្នត្រូវបានអ្នកនយោបាយថៃ និង ក្រុមបញ្ញវន្តអភិរក្សជ្រុលនិយមយកមកប្រើប្រាស់ក្នុងការបំភ្លៃប្រវត្តិសាស្ត្រ ដើម្បីលើកតម្កើងជាតិសាសន៍ថៃ។ លើសពីនោះទៀត គេប្រើប្រាស់បញ្ហាជាតិនិយមក្នុងបំណងបំភាន់ភ្នែកមហាជនខ្លួនឯង ដើម្បីទាញសមាណចិត្តអ្នកគាំទ្រ។ គួរបញ្ជាក់ថា មេចលនា PAD នៅក្នុងជម្លោះនយោបាយផ្ទៃក្នុងចន្លោះឆ្នាំ២០០៨ មកដល់បច្ចុប្បន្ននេះ គេបានប្រើប្រាស់មនោគមជាតិនិយមទឹកដីជះមកលើកម្ពុជាលើបញ្ហាព្រំដែនផងដែរ។

ពាក់ព័ន្ធនឹងបញ្ហាទំនាក់ទំនងកម្ពុជាថៃក្នុងដំណាក់កាលសង្គ្រាមត្រជាក់ បានរអិលធ្លាក់ទៅក្នុងទិដ្ឋភាពតានតឹងមួយទៀត ចាប់តាំងពីប្រទេសថៃចូលរួមក្នុងអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ SEATO ហើយសហរដ្ឋអាមេរិកក៏ដូចជាប្រទេសថៃប្រើមធ្យោបាយគ្រប់រូបភាព ដើម្បីគាបសង្កត់កម្ពុជាឱ្យចូលរួមនៅក្នុងអង្គការសេអាតូ។ សហរដ្ឋអាមេរិកបានបង្កើតកងទ័ពខ្មែរសេរី ដែលបំពាក់អាវុធ និង

ហ្វឹកហ្វឺនដោយពួកសេអ៊ីអានៅក្នុងប្រទេសថៃប្រឆាំងនឹងកម្ពុជា។ ម្យ៉ាងទៀត ករណីកងទ័ពថៃឡើងកាន់កាប់ប្រាសាទព្រះវិហារដោយខុសច្បាប់ក្នុងទសវត្សឆ្នាំ១៩៥០ បានក្លាយទៅជាមូលដ្ឋានចម្បងនៃភាពតានតឹងរវាងកម្ពុជា-ថៃ។

ស្របពេលជាមួយគ្នានេះដែរ សម្ដេចព្រះនរោត្ដម សីហនុ មានការព្រួយបារម្ភពីការរីករាលដាលលទ្ធិកុម្មុយនីស្ដ។ ស្ថានភាពនយោបាយក្នុងប្រទេសកម្ពុជាបានធ្លាក់ក្នុងសភាពតានតឹង នៅពេលដែលសម្ដេចព្រះនរោត្ដម សីហនុ បដិសេធជំនួយអាមេរិកនៅឆ្នាំ១៩៦៣។ តាមការពន្យល់របស់សម្ដេចព្រះនរោត្ដម សីហនុ ថានោះគឺជាអ្វីដែលឆ្លើយតបចំពោះសកម្មភាពក្បត់ចង់ផ្ដួលរំលំព្រះមហាក្សត្រនិងខ្លួនព្រះអង្គផ្ទាល់ដែលនេះគឺជាលទ្ធផលមួយចេញពីគំនិតរបស់សហរដ្ឋអាមេរិក និងក៏ដូចជាការគាំទ្រចំពោះកងទ័ពវៀតណាមខាងត្បូង និង ចលនាខ្មែរសេរីដែលគាំទ្រដោយប្រទេសថៃ។

ការរីករាលដាលនៃលទ្ធិកុម្មុយនីស្ដនៅឥណ្ឌូចិន ជាពិសេសក្នុងប្រទេសកម្ពុជា បានធ្វើឱ្យប្រទេសថៃមានការព្រួយបារម្ភកាន់តែខ្លាំងឡើង។ ហេតុនេះហើយប្រទេសថៃរួសរាន់ប្រកូកប្រកាសបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ទាំងអស់ឱ្យរួបរួមគ្នាឡើង ជាពិសេសគឺការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅថាអាស៊ាន (ASEAN) ដើម្បីប្រឆាំងការរីករាលដាលលទ្ធិកុម្មុយនីស្ដនេះ។ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ បានបង្កើតឡើងនៅឆ្នាំ១៩៦៧ គឺស្របពេលដែលកម្ពុជា កំពុងលេចឡើងយ៉ាងពិតប្រាកដនៃចលនាកុម្មុយនីស្ដប្រឆាំងរដ្ឋាភិបាលដោយកម្លាំងប្រដាប់អាវុធ គឺក្នុងខេត្តបាត់ដំបងដែលជាប់ព្រំប្រទល់ដែនថៃ។ ពួកស្ដាំនិយមកម្ពុជា បានផ្ដួលរំលំសម្ដេចនរោត្ដម សីហនុ ពីអំណាចនៅថ្ងៃទី១៨ មីនា ១៩៧០។ ទំនាក់ទំនងការទូតរវាងកម្ពុជា និង ថៃ ក៏បានបង្កើតឡើងវិញនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧០ បន្ទាប់ពីមានការផ្ដាច់ទំនាក់ទំនងគ្នាតាំងពីក្រោយឆ្នាំ១៩៦២មក។ ក្រុងភ្នំពេញ និង បាងកក បានចុះហត្ថលេខាទ្វេភាគីអំពីសហប្រតិបត្តិការលើគ្រប់វិស័យទាំងវិស័យយោធាផងដែរ។

ផ្អែកលើការសិក្សាភូមិសាស្ត្រនយោបាយ នាយុគសម័យសកលភាវូបនីយកម្ម ដែលប្រកបដោយការប្រកួតប្រជែងខ្ពស់ ហាក់បានធ្វើឱ្យពិភពលោកស្ថិតនៅក្នុងសង្គ្រាមត្រជាក់ថ្មី ដែលបណ្ឌិត សុខ ទូច បានអត្ថាធិប្បាយថាជា «ជំងឺលាប់នៃសង្គ្រាមត្រជាក់»។ នៅក្នុងទិដ្ឋភាពនយោបាយអន្តរជាតិបច្ចុប្បន្នបានគូសបញ្ជាក់ពីសញ្ញាណនៃការបែងចែកប៉ូលនយោបាយ ដែលធ្វើឱ្យជម្លោះអន្តរជាតិកាន់តែរីករាលដាល និង កាន់តែមានភាពស្មុគស្មាញ។ លើសពីនេះទៀត រដ្ឋភាគីជម្លោះប្រកាន់ភាពក្រអឺតក្រទមនៅក្នុងដំណើរការដោះស្រាយវិវាទ។ ដូចគ្នានេះហើយ ទើបអ្នកវិភាគខ្លះបានឱ្យតម្លៃថា «អាស៊ានជារបស់មហាអំណាច»។

សហរដ្ឋអាមេរិក និង ប្រទេសចិន កំពុងតែធ្វើនយោបាយវាទីដែនភូមិសាស្ត្រនយោបាយរៀងៗខ្លួន។ បណ្ដាប្រទេសកំពុងអភិវឌ្ឍមួយចំនួនត្រូវបានចិនចាត់ទុកថា ជាប្រទេសដែលមានចំណុចខ្លាំងរបស់ចិន ដែលមានលទ្ធភាពកសាងឥទ្ធិពលនយោបាយរបស់ប្រទេសខ្លួននៅទីនេះ សំដៅបម្រើឱ្យយុទ្ធសាស្ត្រសេដ្ឋកិច្ចរបស់ចិន និង ឈានទៅពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រនៅក្នុងនយោបាយអន្តរជាតិ។ ប្រការគួរឱ្យកត់សម្គាល់បញ្ហានេះ គេសង្កេតឃើញថា ដើមឆ្នាំ២០១២ ក្នុងឋានៈប្រទេសកម្ពុជាជាប្រធានអាស៊ាន ថ្នាក់ដឹកនាំប្រទេសចិនតែងបានបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជាចំពេលកិច្ចប្រជុំនានារបស់អាស៊ាន។ ពាក់ព័ន្ធនឹងទំនាក់ទំនង ចិន-កម្ពុជា នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១២ ក្រោយ

ពីជំនួបរយៈពេលជាង២ម៉ោងរវាងនាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជា និង លោក ហ៊ូ ជិនតាវ ប្រធានាធិបតីចិននៅវិមានសន្តិភាព សម្តេច ហ៊ុន សែន មានប្រសាសន៍ថា «*យើងដឹងហើយថា ទំនាក់ទំនងរវាងកម្ពុជា និង ចិន បានដើរដល់ជំហានមួយខ្ពស់ គឺថា ទំនាក់ទំនងជាយុទ្ធសាស្ត្រ ជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ*»។

គួរបញ្ជាក់ឡើងវិញថា ក្នុងខណៈកម្ពុជា ទទួលបានជំនួយយោធាពីប្រទេសចិន ស្ថិតចំពេលទំនាក់ទំនងប្រទេស កម្ពុជា-ថៃ ចុះដុនដាប ហើយឈានទៅផ្ទុះសង្គ្រាមទៀតផង។ ដូចគ្នានេះដែរ ចុងឆ្នាំ២០០៩ ប្រទេសថៃដែលជាសម្ព័ន្ធមិត្តអាស៊ីរបស់សហរដ្ឋអាមេរិក ហើយដែលតែងធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសមយុទ្ធយោធាពហុសាសន៍ «ពោះវែកមាស (Cobra Gold)» ជាមួយសហរដ្ឋអាមេរិក បានរៀបចំធ្វើសមយុទ្ធនេះកៀកនឹងខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ។ ការរៀបចំបែបនេះ ត្រូវបានគេមើលឃើញថា ជាការគំរាមកំហែងដល់កម្ពុជា បើទោះជាក្រសួងការបរទេសថៃ បានចេញសេចក្តីពន្យល់ថា ជាការធ្វើសមយុទ្ធប្រចាំឆ្នាំធម្មតាក៏ដោយ។

នៅគ្រប់រដ្ឋាភិបាលថៃចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១១ ដឹកនាំដោយនាយករដ្ឋមន្ត្រីចំនួន៥រូបរួមមាន ៖ ថាក់ស៊ីន ស៊ីណាវ៉ាត់, ស៊ូរ៉ាយុត ជូឡាណុន, សាម៉ាក់ ស៊ុនដារ៉ាវេច, ស៊ុំថៃ វង់សុវ៉ាត់ និង អាភីស៊ិត វេចាជីវ៉ា សុទ្ធតែជានាយករដ្ឋមន្ត្រី ដែលបានដឹកនាំប្រទេសថៃស្ថិតនៅក្នុងភាពវឹកវរនៃជម្លោះនយោបាយផ្ទៃក្នុង។ គួរកត់សម្គាល់ថា នៅពេលមានការផ្លាស់ប្តូរប្រមុខដឹកនាំ ឬ រដ្ឋមន្ត្រីក្នុងពេលនោះ ក៏ផ្លាស់ប្តូរមន្ត្រីនយោបាយថ្នាក់បច្ចេកទេស ហើយបានធ្វើឱ្យទំនាក់ទំនងទ្វេភាគីកាន់តែមានភាពស្មុគស្មាញ។ ជាងនេះទៅទៀត ការបកស្រាយធម្មនុញ្ញថៃ ក៏បានជំរុញឱ្យទំនាក់ទំនងការទូតកាន់តែតានតឹងឡើងរវាងកម្ពុជា និង ថៃ។

ការចូលកាន់កាប់ប្រាសាទព្រះវិហារជាថ្មី ចាប់ពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ បានបង្ហាញពីភាពមិនអស់ចិត្តពីអ្នកជាតិនិយមជ្រុល បូករួមនឹងវិបត្តិនយោបាយផ្ទៃក្នុងរបស់ប្រទេសថៃ ដែលមិនបានបង្ហាញពីការឯកភាពគ្នាលើការដោះស្រាយជាមួយប្រទេសកម្ពុជា។ ពាក់ព័ន្ធនឹងបញ្ហានេះ សាម៉ាក់ ស៊ុនដារ៉ាវេច បានពន្យល់ដល់ការសួរដេញដោលក្នុងសភាថៃ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ថា «*ទង់ជាតិរបស់ប្រទេសកម្ពុជាបានដាក់លើប្រាសាទព្រះវិហារជាង៤៦ឆ្នាំ (គិតនៅឆ្នាំ២០០៨) មកហើយ ហើយគ្មានអ្នកនយោបាយថៃណាមួយបានតវ៉ាឱ្យដកចេញឡើយ*»។ រីឯលោក ណុបប៉ាដុន ប៉ាតាម៉ា បានប្រាប់ទៅសភាថៃ នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៨ ថា «*បញ្ហាប្រាសាទព្រះវិហារ វាស្ថិតនៅក្នុងក្របខណ្ឌច្បាប់អន្តរជាតិ ដែលថៃចាំបាច់ត្រូវតែគោរព*»។ ចំណែកឯ លោក អាភីស៊ិត វេចាជីវ៉ា បានថ្លែងប្រាប់ក្រុមបាតុករអាវលឿង PAD នៅឆ្នាំ២០០៨ ថា «*ខ្លួននឹងយកប្រាសាទព្រះវិហារវិញឱ្យបាន នៅពេលដែលខ្លួនបានធ្វើជានាយករដ្ឋមន្ត្រីថៃបានបីខែ*»។ ផ្ទុយទៅវិញ លោក អាភីស៊ិត ចាញ់ឆ្នោតឆ្នាំ២០១១ ក៏ដោយសារបញ្ហាព្រះវិហារ។ ក្នុងន័យនេះ បានបញ្ជាក់ថាអ្នកនយោបាយថៃបានយល់រួចហើយថា ព្រះវិហារពិតណាស់ជារបស់កម្ពុជា ក៏ប៉ុន្តែថៃបានប្រើប្រាស់បញ្ហាប្រាសាទព្រះវិហារដើម្បីចិញ្ចឹមចលនាជាតិនិយម បម្រើផលប្រយោជន៍នយោបាយផ្ទៃក្នុងរបស់ខ្លួន។ ផ្ទុយពីការលើកឡើងរបស់អ្នកទាំងពីរនេះ ក្រុមអ្នកជាតិនិយមជ្រុលថៃ រួមមាន ក្រុមយោធា បណ្តាញរាជវាំង និង ចលនា PAD នៅតែគិតថា ប្រាសាទព្រះវិហារនៅក្នុងទឹកដីថៃដដែល។ ថៃប្រើប្រាស់សំណុំរឿងប្រាសាទ

ព្រះវិហារ ដើម្បីបញ្ជូនកងទ័ពឱ្យមកឈ្លានពាន បោះទីតាំងនៅតំបន់ប្រាសាទព្រះវិហាររបស់ខ្មែរ ប្រាសាទតាមាន់ធំ តាមាន់តូច និង តាក្របី និងតំបន់ជួរភ្នំដងរែករបស់ខ្មែរ។ ឆ្លើយតបនឹងបញ្ហានេះ កម្ពុជាបានជ្រើសរើស «សមីការគន្លឹះ» មកដោះស្រាយ ដោយនាំយកបុគ្គល ថាក់ស៊ីន ស៊ីណាវ៉ាត់ ហាក់ចូលក្នុងឆាកនៃទីលានវិវាទ ដើម្បីឆ្លើយតបភាពមិនប្រាកដប្រជានៃការកេងចំណេញនយោបាយរបស់ប្រទេសថៃ។ ផ្ទុយទៅវិញសមីការគន្លឹះ កាន់តែធ្វើឱ្យទំនាក់ទំនងកាន់តែធ្ងន់ធ្ងរឡើងថែមទៀត។

ជារួម ប្រទេសថៃបានយល់យ៉ាងច្បាស់នូវដែនបូរណភាពនៃប្រាសាទព្រះវិហារ និង តំបន់ជុំវិញប្រាសាទព្រះវិហារ ថាស្ថិតក្នុងដែនអធិបតេយ្យកម្ពុជា។ ប៉ុន្តែអ្នកយោបាយថៃគ្រាន់តែយកបញ្ហានេះ ធ្វើជាល្បែងនយោបាយផ្ទេរទំនាស់វិបត្តិផ្ទៃក្នុងរបស់ប្រទេសខ្លួនទៅបញ្ហាជាតិនិយមទឹកដី។ ទង្វើនេះត្រូវបានគេមើលឃើញថា ក្នុងរដ្ឋបាលលោក អាភីស៊ីត បានរៀបចំឆាកល្ខោននយោបាយតាមរយៈសេណារីយ៉ូបំភ្លៃប្រវត្តិសាស្ត្រអាវលឿង ដែលជាទូទៅគេដឹងថាគឺជាក្រុមរបស់នាយករដ្ឋមន្ត្រី អាភីស៊ីត និង បណ្តាញរាជវាំង។ ក្នុងន័យនេះ យើងយល់បានថា ប្រសិនបើអ្នកស្រាវជ្រាវថៃ និង អ្នកនយោបាយថៃ មិនប្រកាន់នូវគំនិតអភិរក្សនិយមជ្រុល ហើយបានទទួលស្គាល់តាមសច្ចភាពប្រវត្តិសាស្ត្រពិតនោះ ប្រទេសទាំងពីរ កម្ពុជា-ថៃ នឹងមិនមានអវិភាពច្រើនយ៉ាងនេះនោះទេ។

ដូចបានលើកឡើងនៅចំណុចខាងលើ បញ្ហាផ្ទៃក្នុងថៃនាំឱ្យអ្នកនយោបាយថៃផ្ទេរវិបត្តិនយោបាយរបស់ខ្លួនមកផ្សារភ្ជាប់នឹងបញ្ហាព្រំដែនជាមួយកម្ពុជា។ លោក អាភិស៊ីត បានជាប់ និង ធ្លាក់ពីនាយករដ្ឋមន្ត្រីថៃ សុទ្ធតែពាក់ព័ន្ធនឹង «បញ្ហាប្រាសាទព្រះវិហារ និង ព្រំដែនកម្ពុជាថៃ»។

បញ្ហាព្រំដែនប្រទេសកម្ពុជា ជាមួយប្រទេសជិតខាង បានក្លាយជាប្រធានបទដ៏រសើបនៅក្នុងការឃោសនានយោបាយស្ទើតែគ្រប់គណបក្សនយោបាយកម្ពុជា។ ជាមួយគ្នានេះដែរ មានអ្នកវិភាគខ្លះបានចោទសួរថា ហេតុអ្វីបានជាការបញ្ចូលប្រាសាទព្រះវិហារ ជាសម្បត្តិបេតិកភ័ណ្ឌពិភពលោក នាថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨?។ ម្យ៉ាងទៀត និន្នាការនយោបាយរបស់បក្សប្រឆាំងនៃប្រទេសកម្ពុជា និង ប្រទេសថៃទៅលើបញ្ហាជម្លោះទឹកដីហាក់មានភាពស្របគ្នា។ ក្នុងនោះ យើងអាចមើលឃើញថា ការបំផុសចលនាស្នេហាជាតិរបស់មេដឹកនាំ PAD នៅឆ្នាំ២០០៨ បានផ្តោតជាសំខាន់ទៅលើបញ្ហាព្រំដែន និង ករណីប្រាសាទព្រះវិហារជាមួយកម្ពុជា ស្របពេលជាមួយគ្នាប្រទេសកម្ពុជារៀបចំបោះឆ្នោតសកលនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨។ រីឯគណបក្សដែលមិនគាំទ្ររដ្ឋាភិបាលកម្ពុជា ក៏បានលើកយកបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម ដាក់បញ្ចូលក្នុងកម្មវិធីនយោបាយរបស់ខ្លួនផងដែរ។ ការប្រើប្រាស់ប្រធានបទជាតិនិយម លើករណីព្រំដែនសម្រាប់អ្នកនយោបាយទាំងពីរប្រទេស ថ្វីត្បិតតែបានចំណេញនយោបាយសម្រាប់បក្ស ក៏ប៉ុន្តែវាអាចធ្វើឱ្យបាត់បង់ផលប្រយោជន៍ជាតិ មិនថាប្រទេសថៃ ឬ កម្ពុជាឡើយ។ ដូចបានលើករួចមកហើយ ករណីភាពតានតឹងនយោបាយផ្ទៃក្នុងប្រទេសថៃ ក្នុងពេលដំណាលគ្នាបានធ្វើឱ្យសភាពការណ៍នៅតាមព្រំដែន កម្ពុជា-ថៃ តានតឹងផងដែរ។

រួមសេចក្តីទៅ វិវាទ កម្ពុជា-ថៃ ចាប់ឆ្នាំ២០០៦ ដល់បច្ចុប្បន្ននេះ បានដុតរោលរាលទំនាក់ទំនងនៃប្រទេសទាំងពីរ ដែលអាចនឹងជះឥទ្ធិពលដល់កម្រិតតំបន់ និង អន្តរជាតិផងដែរ។ អាស្រ័យហេតុនេះ ប្រទេសទាំងពីរចាំបាច់ត្រូវស្វែងរកយន្តការដោះស្រាយវិវាទទាំងនោះ ដូចបានលើកយកមកវិភាគនៅជំពូក៣។

**ជំពូក៣៖** ក្នុងរយៈពេល៤៦ឆ្នាំ (គិតត្រឹមឆ្នាំ២០០៨) ប្រទេសថៃមិនដែលតវ៉ាដោយបើកចំហរទៅលើសាលដីកាតុលាការអន្តរជាតិឆ្នាំ១៩៦២នោះទេ។ ប៉ុន្តែ ប្រទេសថៃបានបង្កើតផែនទីឯកតោភាគីសម្រាប់ប្រើប្រាស់នៅពេលណាមួយ ដែលខ្លួនអាចវាតទីចូលដែនដីកម្ពុជា។ ផែនទីនោះមានសរសេរអក្សរ «សម្ងាត់» ដើម្បីលាក់បំបាំងនូវមហិច្ឆតាវាតទីទឹកដីរបស់ថៃ។

លោក ណុបប៉ាដន ប៉ាតាម៉ា កាលនៅធ្វើជារដ្ឋមន្ត្រីក្រសួងការបរទេសថៃបាន ឆ្លើយតបការសួរដេញដោលរយៈពេល ជាងប្រាំពីរប្រាំបីម៉ោងក្នុងសភាថៃនាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៨ថា «*ខ្ញុំសូមជម្រាបថា ដែលមានថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២នេះ ជាថ្ងៃនាំមកនូវភាពសោកសៅដល់ប្រជារាស្ត្រថៃទាំងពួង។ ខ្ញុំអាយុទើបបាន១ខួបប្រហែលមិនសូវបានដឹងរឿងថា ប្រជាជនថៃបាត់បង់អ្វីទៅខ្លះទេ។ ថ្ងៃនោះ ICJ កាត់ក្ដីឱ្យអាណាខេត្តដែលតួប្រាសាទតាំងនៅនោះជារបស់កម្ពុជា ឬ មានការយល់ឃើញថា ប្រាសាទព្រះវិហារតាំងនៅក្នុងវង្វង់អធិបតេយ្យភាពរបស់កម្ពុជា។ យើងមិនត្រូវអធិប្បាយទៀតទេ ថាយើងចាញ់ព្រោះហេតុអ្វីព្រោះរឿងក្តីនេះជាបទដ្ឋាននៃច្បាប់អន្តរជាតិក្នុងរឿង Estoppels Law (ឬ គោលការណ៍ អ៊ីស្តូប៉ែល)*»។ ដោយថ្លែងសំដៅដល់លិខិតមួយច្បាប់របស់លោកវរៈសេនីយឯក ថៈណាត់ ខម៉ាន់ ដែលជារដ្ឋមន្ត្រីការបរទេសថៃនាសម័យនោះបានផ្ញើជូនលោក អ៊ូ ថាន់ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ជាជនជាតិភូមាថា «*ភាគីថៃសូមរក្សាសិទ្ធិដែលមាននៅពេលបច្ចុប្បន្ន ឬ នៅពេលអនាគត ដែលនឹងទាមទារប្រាសាទព្រះវិហារត្រឡប់មកវិញ លោក ណុបប៉ាដន ប៉ាតាម៉ា ថ្លែងថា ការកាត់ក្តីតុលាការអន្តរជាតិ ដែលអាចសើរើដល់ទីបំផុតក្នុងរយៈពេល១០ឆ្នាំ ដូច្នេះ ៤៥ឆ្នាំកន្លងមកនេះ វាហួសអស់ទៅហើយ*»។

មាត្រា៦០នៃលក្ខន្តិកៈ ICJ បញ្ជាក់ថា សាលដីកាតុលាការនេះ បានផ្តល់ឱកាសឱ្យថៃធ្វើការប្តឹងសើរើឡើងវិញក្នុងរយៈពេល១០ឆ្នាំ ប៉ុន្តែថៃមិនបានប្តឹងសុំសើរើក្នុងឆ្នាំ១៩៧២ឡើយ។ ដូច្នេះថៃគ្មានសិទ្ធិរក្សាទុកជាអចិន្ត្រៃយ៍ផ្អែកលើច្បាប់អន្តរជាតិណាមួយ ដើម្បីទាមទារយកប្រាសាទព្រះវិហារ ឬ តំបន់នៅជុំវិញប្រាសាទព្រះវិហារបានឡើយ។

បទពិសោធន៍ដំណោះស្រាយជម្លោះរវាងប្រទេសថៃនឹងប្រទេសជិតខាងថៃកន្លងមក តែងឈរលើគោលការណ៍ដោះស្រាយទ្វេភាគី ដោយមិនមានប្រទេសទីបី ឬ អន្តរាគមន៍អន្តរជាតិណាលូកដៃ។ ជាឧទាហរណ៍ជាក់ស្តែងក្នុងបញ្ហានេះ ប្រទេសថៃមានទំនាស់ព្រំដែនជាមួយប្រទេសឡាវនៅឆ្នាំ១៩៨៤ ថៃមានទំនាស់ព្រំដែនជាមួយប្រទេសម៉ាឡេស៊ីនៅឆ្នាំ១៩៩១ និង ថៃមានទំនាស់ព្រំដែនជាមួយភូមានៅឆ្នាំ២០០១។ ក្នុងចំណោមនេះមានតែជាមួយប្រទេសម៉ាឡេស៊ីមួយទេ ដែលថៃសុខចិត្តដោះស្រាយតាមរយៈការចរចា និង មិនប្រើកម្លាំងយោធា ដោយសារតែប្រទេសម៉ាឡេស៊ីមានឧត្តមភាពជាងប្រទេសថៃ។ តាមរយៈបទពិសោធន៍នេះ បញ្ជាក់ប្រាប់ថា ប្រទេសកម្ពុជាគួរចាំបាច់ពង្រឹងលើសសរស្តម្ភសំខាន់ៗមួយចំនួន ដើម្បីជាយន្តការដោះស្រាយបញ្ហាព្រំដែនជាមួយថៃ ដែលក្នុងនោះរួមមាន ទី១ កម្ពុជាត្រូវពង្រឹងកម្លាំងយោធា៖ ថ្វីត្បិតប្រទេសមានសុខសន្តិភាពពេញលេញផ្ទៃក្នុង ក៏ប៉ុន្តែប្រទេសជាតិនីមួយៗត្រូវមានកម្លាំងតុល្យភាពខាងយោធា មានន័យថាកម្ពុជាអាចនឹងឆ្លើយតបគ្រប់ពេលវេលានៅពេលណាដែលប្រទេសជិតខាងរំលោភបូរណភាពទឹកដី។ ទី២ ឯករាជ្យភាពខាងសេដ្ឋកិច្ច៖ ក្នុងរយៈកាលកន្លងមកការផ្លោះប្តូរសេដ្ឋកិច្ចរវាងប្រទេសកម្ពុជា និង ថៃពុំមានតុល្យភាពនោះទេ ពោលគឺសេដ្ឋកិច្ចកម្ពុជាពឹងអាស្រ័យនឹងសេដ្ឋកិច្ចថៃភាគច្រើន។ ទី៣ ពង្រីកនយោបាយការបរទេស៖ នៅក្នុង

ចំណុចនេះ ប្រទេសកម្ពុជាគួរពង្រឹងបន្ថែមលើទំនាក់ទំនងការទូតព្រមជាមួយនឹងការពង្រីកតួនាទីរបស់ខ្លួននៅក្នុងអង្គការតំបន់ក៏ដូចជា UN ផងដែរ។ លើសពីនោះទៀត កម្ពុជាត្រូវពង្រឹងឱ្យបានកាន់តែរឹងមាំជាមួយប្រទេសមហាអំណាច។ និង ទី៤ ប្រមូលការគាំទ្រពីមហាជននិងបញ្ញវន្តកម្ពុជា៖ នៅក្នុងចំណុចនេះយើងក្រឡេកទៅមើលប្រទេសថៃ ថ្វីត្បិតតែប្រទេសនេះបានបំពានទៅលើបូរណភាពប្រទេសជិតខាង ក៏ប៉ុន្តែបញ្ញវន្តថៃ និង មហាជនថៃតែងតែសម្តែងការគាំទ្ររាជរដ្ឋាភិបាលខ្លួនជានិច្ច។

ក្នុងចំណោមយន្តការទាំងឡាយ ការពង្រឹងទំនាក់ទំនងការទូតស្មើមុខមាត់គ្នាក៏ជួយសម្រាលបន្ទុកវិវាទផងដែរ។ ទិដ្ឋភាពចាស់ និង ថ្មី នៃប្រក្រតីភាពទំនាក់ទំនងការទូតប្រទេសទាំងពីរនៅដើមសតវត្សទី២១ ប្រទេសទាំងពីរក៏ធ្លាប់ជួបនូវទំនាក់ទំនងល្អ ដែលកើតចេញពីទស្សនៈនយោបាយរបស់ថ្នាក់ដឹកនាំនៃរដ្ឋភាគីទាំងពីរ។ គោលនយោបាយ «ធ្វើឱ្យអ្នកជិតខាងមានវិបុលភាព» របស់លោកថាក់ស៊ីន ត្រូវបានសម្តេច ហ៊ុន សែន អបអរហើយហៅនយោបាយនេះថា «ទ្រឹស្តីថាក់ស៊ីន» ដែលសង្កត់ធ្ងន់លើការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងទ្វេភាគី។ ការផ្តួចផ្តើមគំនិតរបស់លោក ថាក់ស៊ីន ដើម្បីស្តារទំនាក់ទំនងក្រោយវិបត្តិដុតទូតថៃ ២៩ មករា ២០០៣ បាននាំមកនូវប្រក្រតីភាពនៃទំនាក់ទំនងរវាងប្រទេសទាំងពីរ។

ទំនាក់ទំនងទ្វេភាគីបានប្រែប្រួលទៅតាមការផ្លាស់ប្តូររដ្ឋាភិបាលនៅប្រទេសថៃ ក្នុងខណៈប្រទេសកម្ពុជាដឹកនាំក្នុងរដ្ឋាភិបាលដោយសម្តេច ហ៊ុន សែន។ ក្នុងចន្លោះរដ្ឋាភិបាលថៃចំនួន០៦នាក់ក្នុងនោះមាននាយករដ្ឋមន្ត្រី ថាក់ស៊ីន ស៊ីណាវ៉ាត់, ស៊ូរាយុត ជូឡាណុន, សាម៉ាក់ ស៊ុនដារ៉ាវេច, ស៊ុំចៃ វង្សសុវ៉ាត់, អាភីស៊ីត វេចាជីវ៉ា និង យីងឡាក់ ស៊ីណាវ៉ាត់។ ចាប់តាំងពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១២ យើងសង្កេតឃើញថា នៅក្នុងរដ្ឋាភិបាលលោក អាភីស៊ីត បានធ្វើឱ្យទំនាក់ទំនងកម្ពុជា-ថៃ តានតឹងខ្លាំងបំផុត។

នៅក្នុងទំនាក់ទំនងមិនផ្លូវការរវាងថ្នាក់ដឹកនាំប្រទេសទាំងពីរត្រូវបានគេមើលឃើញនូវតួនាទីសំខាន់ចំពោះតួអង្គនយោបាយពីរគឺ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន និង លោក ថាក់ស៊ីន ស៊ីណាវ៉ាត់ អតីតនាយករដ្ឋមន្ត្រីថៃ។ ក្នុងនោះយើងសង្កេតឃើញថា ក្រោយពេលដែលប្រទេសថៃបានរៀបចំរដ្ឋាភិបាលថ្មីរួច លោកថាក់ស៊ីន ស៊ីណាវ៉ាត់ បានធ្វើដំណើរទស្សនកិច្ចមកកម្ពុជា (១៦-២៤ កញ្ញា ២០១១) មួយថ្ងៃក្រោយពីដំណើរទស្សនកិច្ចរបស់លោកស្រី យីងឡាក់ ស៊ីណាវ៉ាត់ នាយករដ្ឋមន្ត្រីថៃថ្មី ដែលជាប្អូនស្រីរបស់លោកថាក់ស៊ីន។ ដំណើរទស្សនកិច្ចនេះបានបង្ហាញពីសញ្ញាណនៃការធ្វើឱ្យប្រសើរឡើងនៃជម្លោះនយោបាយរវាងប្រទេសទាំងពីរ។

ជារួម ជំនួបរវាងប្រមុខរដ្ឋាភិបាលរដ្ឋភាគីជម្លោះ បានផ្តល់សារៈសំខាន់សម្រាប់ការសន្ទនាស្វែងរកដំណោះស្រាយវិវាទ តាមយន្តការនានា។ ក៏ប៉ុន្តែការដោះស្រាយដែលទទួលបានផ្លែផ្កាអាស្រ័យទៅលើឆន្ទៈនយោបាយ និង ទិដ្ឋភាពនយោបាយផ្ទៃក្នុងនៃរដ្ឋភាគីនីមួយៗ។ ក្នុងនោះ ជំនួបប្រមុខរដ្ឋាភិបាលរវាងប្រទេសកម្ពុជា និង ប្រទេសថៃ ចាប់ពីក្រោយរដ្ឋប្រហារទម្លាក់លោក ថាក់ស៊ីន ស៊ីណាវ៉ាត់ (ឆ្នាំ២០០៦) រហូតមកដល់ចុងរដ្ឋបាលលោក អាភីស៊ីត វេចាជីវ៉ា (ខែកក្កដា ឆ្នាំ២០១១) ការសន្ទនារវាងប្រមុខរដ្ឋាភិបាលទាំងពីរ ក្នុងនោះរួមមាន ស៊ូរ៉ាយុត ជូឡាណុន, សាម៉ាក់ ស៊ុនដារ៉ាវេច, ស៊ុំចៃ វង់សុវ៉ាត់ និង អាភីស៊ីត វេចាជីវ៉ា នៃភាគីថៃ ជាមួយសម្តេច ហ៊ុន សែន នៃភាគីកម្ពុជា មិនមាន

ដំណោះស្រាយជាក់លាក់ណាមួយកើតឡើងនោះទេ ពេលខ្លះអាចឈានទៅរកភាពតានតឹងថែមទៀត។ នៅត្រង់ចំណុចនេះ យើងគួរចោទសួរថា «តើទំនាក់ទំនងនយោបាយប្រទេសកម្ពុជា-ថៃ វានៅតែប្រែប្រួលទៅតាមការផ្លាស់ប្តូររដ្ឋាភិបាលនៃប្រទេសទាំងពីរដូច្នេះឬ?»។

ពិនិត្យយន្តការគណៈកម្មាធិការព្រំដែនរួម កម្ពុជា-ថៃ JBC រហូតមកដល់ដើមឆ្នាំ២០១២ JBC បានប្រជុំពេញអង្គចំនួន៥លើក បានខកខានមិនបានជួបគ្នាជាង២ឆ្នាំមកហើយ ចាប់ពីឆ្នាំ២០០៩កន្លងមកដោយសារតែបញ្ហាផ្ទៃក្នុងរបស់ប្រទេសថៃ។ គួរបញ្ជាក់ផងដែរថា ក្រោយពីការផ្លាស់ប្តូររដ្ឋាភិបាលថៃ ដែលបានធ្វើឱ្យស្ថានការណ៍តាមព្រំដែនធូរស្រាលមួយរយៈ ក៏មិនបានដោះស្រាយបញ្ហាអ្វីបាននៅឡើយ។ ក្នុងចំណោមព្រំដែនដីគោកប្រវែង៨០៥គីឡូម៉ែត្រ ដែលមានបង្គោលព្រំដែនសរុប៧៣ ហើយបានរុករកឃើញជាថ្មីមកវិញ ៤៨បង្គោលដោយបានឯកភាពទទួលស្គាល់ ២៩បង្គោលមិនឯកភាព១៩ បង្គោល ខណៈ១៥បង្គោលទៀតភាគីទាំង២បានពិភាក្សាគ្នាដើម្បីបន្តស្វែងរកនៅថ្ងៃទី១៣-១៤កុម្ភៈ ឆ្នាំ២០១២នេះ។ បង្គោលសីមាដែលមិនឯកភាពគ្នានោះ ជាទូទៅវាមិនស្ថិតនៅទីតាំងដើម ដែលភាសាអ្នកវិភាគហៅ «បង្គោលសីមាដើរ»។ ឧទាហរណ៍បង្គោលសីមាលេខ៣៤ បានផ្លាស់ប្តូរទីតាំងចូលជ្រៅមកក្នុងដីខ្មែរជម្រៅប្រមាណ៧គីឡូម៉ែត្រពីចំណុចទីតាំងចាស់។ គួរបញ្ជាក់ផងដែរថា កំណត់ហេតុប្រជុំ JBC ចំនួន៣លើកសភាថៃមិនបានផ្តល់សច្ចាប័ននៅឡើយទេ។

យន្តការអាស៊ាននៅក្នុងការដោះស្រាយវិវាទកម្ពុជា-ថៃ ជាវិញ្ញាសាសាកល្បងសម្រាប់អាស៊ានក្នុងការដើរតួនាទីដើម្បីដោះស្រាយជម្លោះរវាងប្រទេសទាំងពីរដែលជារដ្ឋសមាជិកអាស៊ានដូចគ្នា។ គួរបញ្ជាក់ថា នៅក្នុងកថាខណ្ឌទី១ នៃមាត្រាទី១ ធម្មនុញ្ញអាស៊ាន បានបញ្ជាក់ពីគោលបំណងរបស់សមាគមតំបន់នេះថា «ថែរក្សា និង លើកកម្ពស់សន្តិភាព សន្តិសុខ និង ស្ថិរភាព និង ពង្រីកថែមទៀតតម្លៃឆ្ពោះទៅរកសន្តិភាពក្នុងតំបន់»។ រដ្ឋសមាជិកទាំង១០សុទ្ធតែបានបញ្ជាក់ជានាអះអាងអំពីការគោរពគ្នាទៅវិញទៅមក មិនរំលោភបំពានដែនអធិបតេយ្យនៃរដ្ឋសមាជិក និង ការរក្សាសន្តិសុខក្នុងតំបន់ជាដើម។ ក្នុងន័យនេះចង់បញ្ជាក់ថា ធម្មនុញ្ញអាស៊ានបានអះអាងរួចជាស្រេចនូវគោលការណ៍សម្រាប់រដ្ឋសមាជិកក្នុងការគោរពគ្នាទៅវិញទៅមក និង ជាគន្លឹះនៃការដោះស្រាយវិវាទ។

ជំពូក៨ នៃធម្មនុញ្ញអាស៊ាន បានចែងអំពីយន្តការដោះស្រាយវិវាទ (DSMs) ដោយលើកឡើងនៅមាត្រា២២ ក្នុងន័យ តម្រូវឱ្យសមាជិកអាស៊ានត្រូវខិតខំដោះស្រាយជម្លោះទាំងឡាយដោយសន្តិវិធីឱ្យទាន់ពេលវេលា តាមរយៈកិច្ចសន្ទនា ការប្រឹក្សាយោបល់ និង ការចរចា។ ធម្មនុញ្ញនេះបានអនុញ្ញាតឱ្យសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ បង្កើតយន្តការថ្មីក្នុងការដោះស្រាយជម្លោះទៅតាមការចាំបាច់និងនៅគ្រប់វិស័យទាំងអស់ផ្អែកលើកិច្ចសហប្រតិបត្តិការអាស៊ាន។ អាស៊ានត្រូវបានទប់ស្កាត់ដោយគោលការណ៍សំខាន់របស់ខ្លួននោះ ដែលចែងនៅក្នុងសន្ធិសញ្ញា TAC និង បញ្ជាក់បន្ថែមនៅក្នុងធម្មនុញ្ញអាស៊ានឆ្នាំ២០០៨ នៃការគោរពអធិបតេយ្យភាព បូរណភាពទឹកដី និង ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋជាសមាជិក។ មានការដាក់កម្រិតជាចម្បងលើផ្នែកស្ថាប័នផងដែរ ជាតួយ៉ាងការបង្ការទំនាស់មិនមែនជាផ្នែកនៃការលើកលែងជាក់ស្តែងរបស់អាស៊ាននោះទេ ហើយអាស៊ាននៅខ្វះយន្តការដោះស្រាយជម្លោះជាផ្លូវការ។ ហេតុផលដូចនេះ ទើបមានការវិភាគជាច្រើនលើបញ្ហាវិវាទថ្មីៗរវាងកម្ពុជា និង ថៃ ថាជា «វិញ្ញាសាថ្មីសម្រាប់អាស៊ាន» ក្នុងដំណើរស្វែងរកដំណោះស្រាយដែលមានភាពស្មុគស្មាញ និង មិនមានយន្តការប្រាកដនិយមណាមួយ។ ភស្តុតាងជាក់ស្តែងនៃការដោះស្រាយ

វិវាទនេះ បានបង្ហាញឱ្យអ្នកវិភាគឃើញថា កិច្ចប្រជុំកំពូលអាស៊ានលើកទី២០ នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជាដែលរដ្ឋភាគីជម្លោះ ទាំងពីររួមទាំងឥណ្ឌូណេស៊ី ក្នុងនាមជាអ្នកសម្របសម្រួលផង មិនបានលើកពីរបៀបវារៈ ដើម្បីជំរុញដំណើរការដោះស្រាយនោះឡើយ។ ជាងនេះទៅទៀតលោក ហោណាំហុង នៅក្នុងសន្និសីទកាសែតក្រោយកិច្ចប្រជុំប្រកបដោយភាពមិនចុះសម្រុងគ្នាអំពីបញ្ហាសមុទ្រចិនខាងត្បូង ថា «...អាស៊ានមិនមែនជាតួអង្គតុលាការ ឬ ICJ នោះទេ...»។

ជាការពិត អាទិភាពជាចម្បងរបស់រដ្ឋសមាជិកអាស៊ាន ស្ថិតនៅក្នុងគោលដៅផលប្រយោជន៍នៃកំណើនសេដ្ឋកិច្ច ជាជាងការដោះស្រាយជម្លោះនានាក្នុងតំបន់។ រដ្ឋសមាជិកអាស៊ានតែងយល់ថា បញ្ហាសន្តិសុខ និង នយោបាយមិនមែនជាបញ្ហាប្រឈមបំផុតចំពោះអាស៊ាន ហើយសកម្មភាពជាសំខាន់របស់អាស៊ាន គឺការកសាងជំនឿទុកចិត្ត ការពិភាក្សាយ៉ាងស្ងាត់ស្ងៀមអំពីជម្លោះ និង បញ្ហាការទូតនៅក្រោយឆាក។

ប៉ុន្តែការវិវឌ្ឍប្រព័ន្ធភូមិសាស្ត្រនយោបាយពិភពលោកបច្ចុប្បន្ន ទាមទារឱ្យអាស៊ាន គួរហ៊ានកែទម្រង់លើយន្តការ និង ឥរិយាបថដោះស្រាយវិវាទ រវាងរដ្ឋនិងរដ្ឋជាសមាជិក និង រវាងរដ្ឋក្រៅតំបន់ ទើបអាចធ្វើឱ្យអាស៊ានក្លាយជាអង្គការតំបន់មួយ ដែលមានលក្ខណៈរឹងមាំទាំងសេដ្ឋកិច្ច និង នយោបាយ។ ជាឧទាហរណ៍ជាក់ស្តែងបញ្ហាសមុទ្រចិនខាងត្បូង បានញាំញីកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននៅភ្នំពេញនាខែកក្កដា ឆ្នាំ២០១២។

ភាពទន់ខ្សោយរបស់អាស៊ានបានបង្ហាញយ៉ាងច្បាស់ថា រហូតមកដល់ដំណាច់ឆ្នាំ២០១២ អាស៊ានមិនទាន់បានបញ្ជូនអ្នកអង្កេតការណ៍ឥណ្ឌូណេស៊ីមកតំបន់ជម្លោះកម្ពុជា និង ថៃ នៅឡើយនោះទេ។ ផ្ទុយទៅវិញនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ កម្ពុជា និង ថៃ បានសម្រេចសម្រួលកម្លាំងនៅតំបន់PDZ ដោយមិនមានអ្នកអង្កេតការណ៍ឥណ្ឌូណេស៊ីចូលរួម។ ក្នុងករណីនេះយើងអាចទាញសន្និដ្ឋានបានថា «អាស៊ានគ្មានគោលការណ៍ច្បាស់លាស់ណាមួយសម្រាប់ដោះស្រាយនោះទេ» ពោលគឺផ្អែកលើលក្ខណៈពិសេស និង ចៃដន្យប៉ុណ្ណោះ។ ក្នុងន័យនេះត្រូវបានគេវាយតម្លៃថា «អាស៊ានរបស់មហាអំណាច»។

ករណីយន្តការអង្គការសហប្រជាជាតិ, នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១១ ក្នុងអំឡុងពេលដែលកងទ័ពថៃកំពុងបើកការវាយប្រហារដោយបាញ់កាំភ្លើងធំជញ្ជ្រំមកលើប្រាសាទព្រះវិហារ ដែលភាគីកម្ពុជាតែងវាយតម្លៃថា ជាសង្គ្រាមឈ្លានពាន, នាយករដ្ឋមន្ត្រីកម្ពុជា សម្តេច ហ៊ុន សែន បានផ្ញើលិខិតទៅកាន់ប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដើម្បីស្នើសុំធ្វើការកោះប្រជុំជាបន្ទាន់ក្នុងគោលបំណងដើម្បីបញ្ឈប់ការឈ្លានពានរបស់ថៃ។ នៅថ្ងៃដដែលនោះដែរ លោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិបានចេញសេចក្តីថ្លែងការណ៍របស់ខ្លួនមួយ សម្តែងការព្រួយបារម្ភអំពីការប៉ះទង្គិចគ្នាដោយកងទ័ពកម្ពុជា-ថៃ នៅតាមបណ្តោយព្រំដែនរវាងប្រទេសទាំង២ និង អំពាវនាវឱ្យភាគីទាំង២កាត់បន្ថយជម្លោះអំពើហិង្សា និង ផ្តើមឡើងមកវិញនូវកិច្ចពិភាក្សាគ្នាដើម្បីដោះស្រាយជម្លោះដោយសន្តិវិធី។ នៅក្នុងយន្តការពហុភាគីនេះ ជាពិសេសក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ ភាគីកម្ពុជាបានបង្ហាញពីឆន្ទៈស្វែងរកដំណោះស្រាយប្រកបដោយសន្តិវិធី។

បន្ទាប់ពីនាយករដ្ឋមន្ត្រី ហ៊ុន សែន សរសេរទៅUN, ប្រមុខរដ្ឋាភិបាលថៃ លោក អាប់ភីស៊ីត វេចាជីវ៉ា ក៏បានសរសេរលិខិត២ ច្បាប់ផ្ញើទៅប្រធានមហាសន្និបាតអង្គការសហប្រជាជាតិ និង ប្រធាន

ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដូចគ្នា។ នៅក្នុងលិខិតនោះនាយករដ្ឋមន្ត្រីថៃបានប្រាប់ UN ថា «*កម្ពុជាបានឈ្លានពានបូរណភាពដែនដីថៃ*»។ ការប្រកាសដូច្នេះ នាយករដ្ឋមន្ត្រីកម្ពុជា បានថ្លែងដោយសម្តីខ្លាំងៗទាមទារឱ្យលោកនាយករដ្ឋមន្ត្រីថៃ អាប់ភីស៊ីត វេចាជីវ៉ា ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាម។ ឧក្រិដ្ឋកម្មសង្គ្រាម ដែលកងទ័ពថៃ ប្រព្រឹត្តចាប់តាំងពីថ្ងៃ៤ ខែកុម្ភៈ ឆ្នាំ២០១១ បានបាញ់លើប្រាសាទព្រះវិហារ ដែលជាសម្បត្តិបេតិកភ័ណ្ឌពិភពលោក។

បន្ទាប់ពីការស្នើពីភាគីកម្ពុជាមក UNSC បានសម្រេចចិត្តរៀបចំកិច្ចប្រជុំ «ដោយឡែកមួយ (private meeting) បានអនុញ្ញាតឱ្យរដ្ឋមិនមែនសមាជិក UNSC ៣បានចូលរួមប្រជុំ និង បញ្ចេញមតិដោយអាចឱ្យផ្សព្វផ្សាយជាសាធារណៈ។ នៅក្នុងកិច្ចប្រជុំនេះ លោក ម៉ាទី ណាតាឡេហ្គាវ៉ា បានស្នើជម្រើសបី UNSC ទី១).ភាគីជម្លោះទាំងពីរចង់បានដំណោះស្រាយដោយសន្តិភាព និង ដោយព្រមទទួលយកកាតព្វកិច្ចអាស៊ាន។ ទី២).ស្ថានការណ៍ត្រូវឱ្យនូវសភាពដើម, ស្ថានការណ៍តានតឹងកើតឡើងដោយពុំមានការបកស្រាយច្បាស់លាស់។ ដើម្បីបំពេញកិច្ចការនេះ តម្រូវឱ្យមានធន្ទៈនយោបាយបញ្ឈប់ការផ្ទុះអាវុធ។ ទី៣). គាត់បានផ្តល់ចំណាប់អារម្មណ៍ថា «យើងទាំងអស់គ្នាបានពិភាក្សារួចហើយ ថាតើជ្រើសយកទ្វេភាគី ឬ កម្រិតពហុភាគី។ ជម្រើសដាក់ចេញមកអាចកម្រិតទ្វេភាគី ដែលមានអាស៊ានដើរតួសម្របសម្រួល និង ដោយមានការគាំទ្រពីUNSC។ លទ្ធផលប្រជុំ UNSC នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ បានចេញសេចក្តីថ្លែងការណ៍មិនខុសពីកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានក្រៅផ្លូវការនៅទីក្រុងហ្សាការតានោះទេ។ ខ្លឹមសារសេចក្តីថ្លែងការណ៍រួមមាន «ប្រទេសទាំងពីរត្រូវអត់ធ្មត់ដល់កម្រិតអតិបរមា», «ឈប់បាញ់ជាអចិន្ត្រៃយ៍» និង «ដោះស្រាយដោយសន្តិវិធី និងក្នុងកម្រិតពិភាក្សាស៊ីជម្រៅ»។ សេចក្តីថ្លែងការណ៍មិនបានបង្ហាញសុទិដ្ឋិនិយមការទូតរបស់ភាគីជម្លោះនោះទេ, ភាគីថៃបរាជ័យក្នុងការរារាំង UNSC ចូលមកពាក់ព័ន្ធនឹងបញ្ហានេះ, រីឯកម្ពុជាពុំមានសំអាងគ្រប់គ្រាន់ដើម្បីយកកម្លាំងអង្កេតការណ៍អង្គការសហប្រជាជាតិ។ ប៉ុន្តែ UNSC ក៏បានកត់សម្គាល់បីចំណុចថា ជម្លោះនេះបានអូសបន្លាយយូរ, បានពិភាក្សារវាងរដ្ឋសមាជិកអាស៊ាន និង បានបង្វែរជម្លោះនេះទៅកម្រិតតំបន់វិញ។

ករណីយន្តការតុលាការយុត្តិធម៌អន្តរជាតិ, ICJ ស្ថាប័នដែលសំខាន់ជាងគេរបស់អង្គការសហប្រជាជាតិ នៅក្នុងការដោះស្រាយជម្លោះគឺ ស្ថាប័នតុលាការអន្តរជាតិ។ ស្តីអំពីអធិបតេយ្យភាពនៃតំបន់ប្រាសាទព្រះវិហារ ICJ សម្រេចចេញដីការបស់ខ្លួននៅឆ្នាំ១៩៦២ ដោយបានបញ្ជាក់ច្បាស់ថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងអធិបតេយ្យប្រទេសកម្ពុជា។ ចាប់ពីឆ្នាំ២០០៨មក ប្រទេសថៃ ចាប់ផ្តើមប្រើយុទ្ធសាស្ត្រថ្មីទៀតដោយមិនអើពើនឹងសាលដីកា ICJ ឆ្នាំ១៩៦២ និង បានបញ្ជូនទ័ពចូលតំបន់នេះសាជាថ្មី ដែលបង្ខំឱ្យកម្ពុជាប្រើយន្តការ ICJ នេះឡើងវិញនៅឆ្នាំ២០១១។

សំណុំរឿងចាស់ ប៉ុន្តែយុទ្ធសាស្ត្រថ្មី, ក្រុមអភិរក្សជ្រុលនិយមថៃ បានបំផុសគំនិតជាតិនិយមជ្រុលរបស់អ្នកនយោបាយថៃ ដោយយកតំបន់ប្រាសាទព្រះវិហារធ្វើជាល្បែងនយោបាយ បានជំរុញឱ្យប្រទេសកម្ពុជាសម្រេចចិត្តបិទផ្លូវចរចាទ្វេភាគី។ កម្ពុជាបានយកបញ្ហាថៃឈ្លានពានប្រាសាទព្រះវិហារនេះទៅដោះស្រាយនៅសហគមន៍អាស៊ាន, អង្គការសហប្រជាជាតិ, ហើយចុងក្រោយកម្ពុជាបានសម្រេចចិត្តស្នើសុំទៅ ICJ ឱ្យធ្វើការបកស្រាយឡើងវិញនូវសាលដីកាឆ្នាំ១៩៦២ ដែលសម្រេចឱ្យកម្ពុជាឈ្នះក្តីក្នុងរឿងប្រាសាទព្រះវិហារ។ នៅថ្ងៃទី២៨ ខែមេសាឆ្នាំ២០១១ កម្ពុជាបានដាក់ពាក្យ

ស្នើទៅ ICJ ដើម្បីសុំឱ្យបកស្រាយសាលក្រមឆ្នាំ១៩៦២ និង ចាត់វិធានការបន្ទាន់ (Conservatory Measure)។ ការដាក់ពាក្យស្នើសុំនេះ ដោយកម្ពុជាសំអាងថា មានការឈ្លានពានដោយអាវុធពីសំណាក់ប្រទេសថៃ ដើម្បីដណ្តើមទាមទារយកទឹកដីកម្ពុជា ដោយផ្អែកទៅតាមផែនទីឯកតោភាគីដែលគ្មានមូលដ្ឋានច្បាប់។ យោងតាមបណ្តឹងកម្ពុជា ICJ បានសម្រេចចេញដីកាបង្គាប់លេខ 2011/18July/General List/No.151។ ដីកានេះតម្រូវឱ្យភាគីទាំងពីរដកកងទ័ពជាបន្ទាន់ចេញពីតំបន់គ្មានកងទ័ពជាបណ្តោះអាសន្ន (PDZ) ដែលបានកំណត់ក្នុងផែនទីចំណុច A.B.C.D. ដើម្បីធានាបាននូវការចេញ-ចូល ដោយសេរីរបស់កម្ពុជាទៅកាន់ប្រាសាទព្រះវិហារ និង រក្សាទុករដ្ឋបាលជាប្រក្រតី។ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមានហើយ ភាគីទាំងពីរស្នើសុំឱ្យមានការចាត់តាំង និង បញ្ជូនអ្នកសង្កេតការណ៍ឥណ្ឌូណេស៊ី។

ពាក់ព័ន្ធនឹងបញ្ហានេះ លោក ថាក់ស៊ីន ស៊ីណាវ៉ាត់ អតីតនាយករដ្ឋមន្ត្រីថៃ ក្រោយពីប្អូនស្រីរបស់លោកបានជាប់ជានាយករដ្ឋមន្ត្រីភ្លាមៗ បានសម្តែងការព្រួយបារម្ភពីជម្លោះក្នុងចំណោមពលរដ្ឋថៃនឹងកាន់តែរីករាលដាលក្តៅគគុកឡើងវិញជាក់ជាមិនខាន ប្រសិនបើ ICJ នឹងបកស្រាយ ដូចសាលដីកា ១៥ មិថុនា ១៩៦២ ដែលកាត់សេចក្តីឱ្យភាគីថៃចាញ់ក្តីក្នុងករណីតំបន់ប្រាសាទព្រះវិហារនោះ។ ការសម្តែងការព្រួយបារម្ភរបស់លោក ថាក់ស៊ីន ព្រោះក្នុងដំណាក់កាលតុលាការយុត្តិធម៌អន្តរជាតិឡាអេកំពុងពិនិត្យលើសំណើរបស់ប្រទេសកម្ពុជា ដែលបានទាមទារឱ្យថៃដកកងទ័ពរបស់ខ្លួនចេញពីតំបន់ប្រាសាទព្រះវិហារ។ លទ្ធផលនៃការជ្រើសរើសយកយន្តការ ICJ បានធ្វើឱ្យសភាពការណ៍ជម្លោះនៅព្រំដែន ឈានរកភាពធូរស្រាល និង អនុវត្តបាននូវបទឈប់បាញ់ហើយបានឈានទៅសម្រួលកម្លាំងពីតំបន់ PDZ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២។ ទោះជាយ៉ាង ក៏យើងនៅតែអាចវាយតម្លៃបានថា ប្រក្រតីភាពនៃទំនាក់ទំនងទ្វេភាគីនេះ វានៅតែអាស្រ័យទៅលើទិដ្ឋភាពសង្គមនយោបាយនៃប្រទេសទាំងពីរផងដែរ។

ក្រៅពីយន្តការផ្លូវការដូចបានលើកឡើងខាងលើ ក្នុងនោះយន្តការបន្ទាប់បន្សំ និង យន្តការក្រៅផ្លូវការក៏ជាជម្រើសសម្រាប់ដោះស្រាយវិវាទផងដែរ។ បន្ទាប់ពីបោះឆ្នោតនៅប្រទេសថៃនាឆ្នាំ ២០១១ ថ្នាក់ដឹកនាំនៃបក្សភឿថៃ និង បក្សប្រជាជនកម្ពុជា (ដែលជាបក្សកំពុងដឹកនាំរដ្ឋាភិបាលកម្ពុជា) បានរៀបចំការប្រកួតបាល់មិត្តភាព (Friendly Football Match) ដែលអ្នកកាសែតបស្ចិមប្រទេសហៅថា ការទូតបាល់ទាត់ (Football Diplomacy) នៅពហុកីឡដ្ឋានរាជធានីភ្នំពេញនាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១១។ នៅក្នុងពិធីបើកការប្រកួតបាល់ទាត់នេះ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានថ្លែងថា «*...ថ្ងៃនេះក៏ជាសារនយោបាយមួយដែលបញ្ជូនចេញពីរាជធានីភ្នំពេញ ប្រទេសកម្ពុជា ជូនចំពោះប្រជាជន និងកងទ័ពកម្ពុជា ប្រជាជននិងកងទ័ពថៃ ជាពិសេសអ្នកដែលរស់នៅតាមព្រំដែនកម្ពុជា-ថៃ ដែលសុបិនអាក្រក់ ដែលបានកើតឡើងកន្លងទៅក្នុងទំនាក់ទំនងរវាងប្រទេសទាំងពីរត្រូវបានបញ្ចប់ហើយ។ យើងកំពុងធ្វើកិច្ចការទាំងឡាយដែលនាំមកនូវការពង្រឹងសន្តិភាព មិត្តភាពសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ...*»។ ខាងភាគីថៃ ដែលដឹកនាំដោយ ស៊ុមឆាយ វង្សសុវ៉ាត បានទទួលថា នេះជាសារនយោបាយមួយនឹងឈានទៅរកទំនាក់ទំនងជាធម្មតាឡើងវិញ។

ជាសន្និដ្ឋានរួមការសិក្សាលើប្រធានបទនេះ បានបង្ហាញឱ្យឃើញថា ប្រទេសកម្ពុជា និង ថៃ ពុំទាន់ធ្លាប់នូវទំនាក់ទំនងប្រកបដោយការទុកចិត្តគ្នានៅឡើយនោះទេ។ ម្យ៉ាងទៀត ទំនាក់ទំនងនេះតែងប្រែប្រួលខ្លាំងទៅតាមអថេរមួយចំនួន ដែលយើងមើលឃើញថា វាបានប្រែប្រួលទៅតាមរលកនយោបាយផ្ទៃក្នុងនៃប្រទេសទាំងពីរ។

រូបមន្តដោះស្រាយវិវាទដែលជាប់ជំពាក់នឹងអថេរ ដូចបានលើកឡើងខាងលើតម្រូវឱ្យប្រទេសកម្ពុជាឈរនៅលើគោលជំហររឹងមាំសំខាន់ៗដូចជា៖ វិស័យការពារជាតិ នយោបាយការបរទេស ភាពជាម្ចាស់ការលើភូមិសាស្ត្រនយោបាយ ឯករាជ្យភាពសេដ្ឋកិច្ច ព្រមទាំងមានឯកភាពជាតិទាំងស្រុង។

# Summary

The political waves of the two countries, especially those of Thailand in this new century, have caused hostility in the relationship between Cambodia and Thailand. Thai politicians, Bangkok elites and conservative intellectuals and extremists have been exploiting Thai nationalism, trying to falsely change the history to boast their nation. The Preah Vihear temple dispute was used as a tool to feed nationalism so as to serve Thai political interests. Moreover, nationalism was also used to deceive the public for them to provide more political supports. In this sense, we learn that if Thai politicians had not adopted this extreme conservative nationalism and had turned instead to acknowledge the historical facts of the two countries, Cambodia and Thailand would not have had such enmity towards each other.

**Chapter 1:** Studies on history show that Thailand always exploited the Cambodia-Thailand bilateral relationship even before the colonial period, and especially when Cambodia became weak, Thailand seized the opportunity to implement its territorial expansion policy. During World War II (1939-1945) when the French became weak, Thailand signed a treaty of alliance with Japan and demanded the territories it claimed previously lost to Cambodia. The Franco-Thai war broke out between October 1940 and 09 May 1941. With the Japanese intervention, the war ended in May and Thai troops came into Cambodia territories. At that time, the Thai military government led by Plaek Pibulsonggram categorically denied the ownership of Cambodia over the northwestern territory of Cambodia; he claimed it for Thailand.

The disputes surrounding sovereignty was a complicated issue between Thailand and colonial powers especially the French. Consequently, there were a number of treaties, conventions and agreements, for example the 1867 Franco-Thai Treaty; Franco-Thai Treaties of 1893, 1904 and 1907; the Franco-Thai Peace Convention of 9 May 1941; and the Franco-Thai Agreement of 17 November 1946. Thailand formed many nationalist movements against the colonialists in the hope of governing the territories it claimed previously lost to Cambodia.

Between 1946 and 1949, the Thai government paved the way for the Khmer communists (communist Issarak) and the free Khmer Issaraks (the rightists) to transport ammunitions across Thailand. This Thai political behavior towards both Khmer Issarak Movements, which had different political trends, fostered a movement

to expel French colonialism out of Cambodia – giving Thailand the opportunity to be the master of the fate of Cambodia. Moreover, Thailand always held the belief, so did the French, that Cambodia would grow very weak after it gained independence from France. Furthermore, the Thai envisaged the political ideologies of the two movements would fight not only against the French but also amongst the Khmer. Thailand could also use the two movements to get some territories it claimed previously lost to Cambodia because of the French. Concerning Thailand's interference at the time, Cambodian Prime Minister Hun Sen said on 13 June 2012 that "...before one Cambodian king was crowned in Bangkok..." It is noted that although in 1949 France did not grant Cambodia full independence as yet, the United States and Thailand already acknowledged Cambodian Independence on 11 July 1950 and set up their embassies in Cambodia on 19 December 1950.

In this regard, Thai and U.S. policies are parallel with one another, but the difference is that the US opened its embassy in Cambodia to oppose former colonial powers such as France and England, as well as to prevent the spread of communism in Indochina. And as for Thailand, it rushed to support Cambodia because it wanted the French colonial power out of Cambodia because the French had once driven away the Thai from the region since 1867; besides, Thailand would easily defeat Cambodia as it underwent military and economic downturn.

To sum up, we will answer this key question: "Why did Thailand hurriedly acknowledge Cambodian independence and opened its own embassy in Cambodia on 19 December 1950 before the French handed it down to Cambodia ?" The answer is because Thailand wanted to see Cambodia weak without the help from the superpower.

During Khmer Republic period, although Cambodia turned to forge diplomatic relationship with the US, a superpower who was allied with Thailand, it is noted that the Cambodian-Thai relationship could not return to normality. Thailand saw that the internal conflicts of the Khmer Republic would make Cambodia strong. Moreover, although it was seen that Thailand supported the Khmer Issarak Movements in order to drive away communism and colonialism [out of Cambodia], the actual intent was for a worm to be implanted and burrowed from within Cambodia.

In 1980s, within the framework of the Association of South-East Asian Nations (ASEAN), not only did Thailand, in its capacity of a neighbouring country, fail to help putting out the fire of internal conflicts in Cambodia, it also partook in the Chinese political forum waging war against Cambodia and Indochina while other nations in the region, especially Indonesia, considered China a danger to ASEAN. When Thailand and China were discussing building up a Chinese arsenal in Thailand, ASEAN nations with varying degree were all concerned. Under this circumstance, we can see that although Thailand expressed strong disapproval of King Norodom Sihnouk concerning the issues of Preah Vihear temple and some provinces which Thailand was forced to turn over to Cambodia after WW II, Thailand still gave supports to King Norodom Sihanouk in the fight against the Phnom Penh government to favour its geopolitical strategies and economic interests as Thailand at that time did business with those opposing the Phnom Penh government. Strategically, Thailand did not allow King Norodom Sihanouk to gain enough power of control. King Norodom Sihanouk admitted that "*in comparison to the assistance the Chinese has given to my troops, I only got 10% from Thailand;*" adding that "*Thailand does not want to see Sihanouk strong and wants the Khmer Rouge to have control over the coalition government. Thailand hates Sihanouk and does not want Sihanouk*".

Taking into account the end of the Khmer Rouge regime in the late 1990s, the rise and the fall of the Khmer Rouge undeniably was involved with Thailand. *Ta* Mok's economic activities in Anlong Veng depended solely on Thailand. Thailand always took its stand against communism, but on what principle was its close relationship with the Khmer Rouge held? Was it purely for Thai economic interests or was it a combination of both Thai economic interests and interference into the Cambodian internal affairs?

These arguments were usually raised by Prime Minister Hun Sen, the present Head of the Royal Government of Cambodia, when the tensions in border dispute between 2008 and 2011 became intensified. He stated that "*...Thailand always involved itself in Cambodian internal politics in the 1980s and in the 1990s...*" Moreover, in the Paris Peace Talks, Samdech Hun Sen underlined the role of Thailand in cajoling the Tripartite into accepting the idea of establishing the Council for National Reunion and into blocking the relationship between the Khmer Rouge and Thailand.

In conclusion, the historical conflicts between Cambodia and Thailand before 2006 have indicated the uncertainty of the relationship between the two nations. Throughout the development of the Cambodian politics before and after the colonial regime, Cambodia was abused by Thailand on many occasions, leading to a series of conflicts as explained in Chapter 2 below.

**Chapter 2:** The uncertainty of Thai political system has led to the instability of its executive power and the loss of power balance. It is seen that the Thai government has no right to control the military. For example, in 2008, Thai troops came into the Preah Vihear Temple area, and when Cambodia asked for the withdrawal of the troops, Thailand replied that it needed to ask the parliament first. In the early political mandate of Yingluck Shinawatra, former Thai Prime Minister Thaksin Shinawatra expressed his concern that the conflicts amongst Thai people would be unavoidably more heated once again if the ICJ were to interpret the 15 July 1962 indictment, judging that Thai had lost the case of Preah Vihear temple to Cambodia.

The royal palace's power and lèse majesté laws (lese-majesty laws) also weigh in the political balance in Thailand. This power was evaluated by Western analysts that "The King power is above the stipulated constitution" and that the Thai King is a new institution exerting its influence over politics, which can be called "Network Monarchy". Seeing the influence of this political network, Mr. Thaksin Shinawatra, two-term elected premier in 2001 and 2005, established a policy to replace Network Monarchy with a new network, which was one of the many causes that led to the military coup in 19 September 2006.

According to the US embassy cables released by Wikileaks and republished later by the British paper, *The Guardian*, former Thai Prime Minister Samak Sundaravej said Bhumibol Adulyadej's wife was a key player in 2006 coup d'état, which ousted Prime Minister Thaksin. According to *The Guardian*, which extracted some points in the US cables, former Prime Minister Samak Sundaravej had a talk with Bangkok-based U.S. diplomats in October 2008, one month after he had resigned from his position as the party leader and his position as the prime minister. He told the embassy officials that he believed Queen Sirikit Kittiyakara encouraged the coup ousting Prime Minister Thaksin Shinawatra.

The Thai military were also involved in the 2006 coup d'état, based on the economic and socio-political interests of Thailand. In this sense, it is seen that Thaksin's economic development approach really took a toll on the advantages of the military because this group owned many big enterprises in Thailand. The 2006 coup, moreover, helped them expand their power in Thai internal politics as well as the military expense.

"New thinking, new implementation" is the motto Thaksin always addressed to the public, meaning that "I am a politician who has real purposes to salvage the country from serious crises in 1997". The Pro-Poor Policies boosted Thaksin's popularity to be more widespread amongst peasants and the poor throughout the country, which can be evaluated as the reason for the military coup ousting Thaksin Shinawatra on 19 September 2006. Thaksin's popularity in the last decade was close to that of the King, causing a protest movement against him in many cases. This movement was led by the People's Alliance for Democracy or the "Yellow Shirts PAD".

In this sense, we can draw a conclusion that for Yingluck's government but also for the entire political situation in Thailand, it is difficult to tell about the political stability so long as the Network Monarchy such as the king's men and the military still possess strong power.

The Yellow Shirts or the People's Alliance for Democracy (PAD) was created to protest against Thaksin and his alliance. PAD began their involvement in Thai political crises in 2005-2006 and 2008 as well as Cambodian-Thai border dispute. The prominent members in this group include the royalists, the upper-class and middle-class business Bangkokians, the conservative intellectuals, and the southerners, supported by some factions of the Thai army and some leaders of Democrat Party. During the protests, they requested that the Thai military and conservative group hold important political powers. Furthermore, the movement even sparked anger against Cambodia. A Thai Minister of Foreign Affairs, a key leader of PAD, insulted Cambodia's Prime Minister calling him "a gangster" and even added that "[He] will use Hun Sen's blood to clean his feet".

It is noted that PAD have described themselves as nationalists and declared their protest against any individual and party that do harm to Thai territorial integrity. With this move, PAD opposed Samak's administration, which supported the listing of Preah

Vihear temple as a world heritage while PAD still claimed 4.6 square kilometer of land around the temple as belonged to Thailand. PAD condemned the leader of PPP (People's Power Party), saying that Thaksin had provided benefits to Cambodia in a modern city development project in Koh Kong province of Cambodia. In addition, it also called for the withdrawal of Thai investors from Cambodia, the closure of all Thai-Cambodian border checkpoints, a ban on all flights from Bangkok to Phnom Penh and Siem Reap, and abolishment of the committee which oversees the demarcation of overlapping sea waters.

Today, nationalist movement is used by Thai politicians and extreme conservative intellectuals to distort the history in order to exalt Thai nationals and even to mislead Thai people to attract sympathy from supporters. It is noted that during the internal political conflicts since 2008 the PAD leaders have imposed nationalist ideology on territorial issues against Cambodia.

Cambodia-Thai relationship during the Cold War slid into another tension since Thai joined The South East Asia Treaty Organization (SEATO) and the US as well as Thailand utilized all sorts of methods to pressure Cambodia to join SEATO. The US created armed Free Khmer Troops trained by the CIA in Thailand in order to fight against Cambodia. Moreover, the Thai troops' unlawful occupation of Preah Vihear temple in 1940 became the main cause of tension between Cambodia and Thailand.

At the same time, King Norodom Sihanouk worried about the spread of communism. The political situation in Cambodia faced more tensions when King Sihanouk denied the U.S. assistance in 1963. As he explained, that was his response to the traitorous activity that aimed at overthrowing the monarchy and himself – the idea which came from the US supported by South Vietnamese troops and Free Khmer movement supported by Thailand.

The spread of communism in Indochina, especially in Cambodia, caused more concern for Thailand. Therefore, Thailand promptly appealed to all countries in Southeast Asia to get together to form an Association of Southeast Asian Nations (ASEAN) in order to prevent the spread of communism. ASEAN was formed in 1967 exactly when the communist armed forces emerged against the government in Battambang province near Thai border. The Khmer Rightists overthrew King Sihanouk on March 18, 1970. Diplomatic relations between Thailand and Cambodia was re-

established on May 13, 1970 after they were severed in 1962. Phnom Penh and Bangkok signed bilateral cooperation in all sectors, including the military.

According to the geopolitical study, the highly competitive era of globalization seemingly drives the world into a new cold war that Dr. SOK Touch commented as "a relapse of cold war". Today's international political landscape underlines the notion of political differentiations, making international conflicts more widespread and complicated. In addition, state parties to the dispute adopt arrogant attitudes in the conflict resolution process. As such, some analysts put it that "ASEAN belongs to the superpowers".

The USA and China are adopting expansionism to enlarge their respective political geography. Some developing countries are already seen as china's country strength, enabling it to build political influence in order to serve as its economic strategy and to strengthen partnership in international politics. Remarkably, in early 2012, as Cambodia was the host of ASEAN, China's leaders always paid a visit amid ASEAN summits. Relating to China-Cambodia relations, on March 31, 2012 after a meeting that last over two hours between Cambodia's Prime Minister and Chinese President HU Jintao in the Peace Palace, Samdach HUN Sen said " we know that Cambodia-China relation has reached a high level; it's a strategic relation, a strategic partnership in all areas."

It is worth noting once again that Cambodia received military aids from China while Cambodia-Thailand relations were stormy and was bound to war. Likewise, at the end of 2009, Thailand, as an Asian ally of the U.S. and the host of multi-national "Cobra Gold' military exercise with the U.S., organised the exercise very close to the Cambodia-Thailand border. This move was seen as a threat to Cambodia even though Thai Ministry of foreign affairs explained it was just a normal annual military exercise.

Since 2006 to 2011, Thai government was led by five prime ministers such as Thaksin Shinawatra, Surayud Chulanont, Samak Sundaravej, Somchai Wongsawat, and Abhisit Vejjajiva, who took office amidst the internal political chaos. It is noticeable that when leaders or ministers were changed during that time, so were technical officials. This has further complicated the bilateral relations. The interpretation of the Thai constitution, moreover, has strained Cambodia-Thai relations.

The new presence of the Thai troops at Preah Vihear temple since July 15, 2008 reflected the dissatisfaction of the nationalist extremists, as well as the internal political crisis in Thailand that showed no agreement in resolving the conflict with Cambodia. Regarding this, Samak Sundaravej explained during a debate in the Thai parliament on June 30, 2008 that "*Cambodia's flag has been placed on Preah Vihear temple for over 46 years (by 2008), and no Thai politicians have come to ask for its removal*". And Noppadon Pattama told the Thai parliament on June 27, 2008 that "*the Preah Vihear issue is under international legal framework with which Thailand has to comply*". Abhisit, in turn, addressed to the yellow shirts PAD in 2008 that "he would claim back Preah Vihear temple when he was in office for three months". However, Abhisit lost the 2011 election due to the Preah Vihear issue. In this sense, it is clear that Thai politicians did understand that Preah Vihear indeed belongs to Cambodia, but Thailand used this issue to stir the nationalist movement in order to gain interests for its internal politics. Contrary to the statements made by the two, the Thai nationalist extremists such as the military group, the monarchy network, and the PAD movement still think that the temple is located within the Thai territory. Thailand used the Preah Vihear case to send troops to invade Cambodia, stationing the troops in the Preah Vihear temple area, Tamone Toch temple, Ta Krobei temple, and the Dang Rek mountain range – all in Cambodia. In response to this problem, Cambodia chose a "key equation" solution. Thaksin Shinawatra was brought in as a key person in the conflict. This responded to the uncertain exploitation of Thailand's politics. Nonetheless, the "key equation" strategy worsened the tie between the two countries.

In sum, Thailand fully understood that Preah Vihear Temple and its surrounding vicinity are under the sovereignty of Cambodia. However, Thai politicians used the issue as a political game changing its internal conflict into territorial nationalism. This reflected Abhisit administration plotted a political farce with deceiving scenarios of the history played by the yellow shirts, widely known as associated with Prime Minister Abhisit and the monarchy network. In this sense, it is understood that if Thai politicians and researchers had not adopted the conservative extremist view and instead acknowledged the historical facts, the two countries would not have held antagonism toward one another.

As mentioned above, Thai politicians changed their internal conflict into Cambodian-Thai border issue. The rise and the fall of former Prime Minister Abhisit were all connected with the issue of "Preah Vihear Temple and Cambodia-Thai border".

Cambodian border dispute with its neighbor became a sensitive issue in political campaigns of virtually all political parties in Cambodia. Meanwhile, some critics asked why Preah Vihear temple was listed as a world heritage site on 7 July 2008. Moreover, the political trend of the Opposition Party in Cambodia and that of Thailand on the territorial dispute seem parallel. In this respect, it is seen that the patriotism movement initiated by the leaders of PAD in 2008 focused mainly on border issue and the case of Preah Vihear temple with Cambodia while Cambodia conducted its general election on 27 July 2008. Anti-government political parties in Cambodia also included the border issue with Vietnam in its policy program. The use of nationalism on border issues by political parties of both nations, though gaining political interests for the parties, can disadvantage the two nations, Cambodia and Thailand. As mentioned above, the internal political tension in Thailand at the same time created tension at Cambodian-Thai border.

In conclusion Cambodian-Thai border disputes from 2006 to present soured the relation of the two countries and could yield impact regionally and internationally. Therefore, both nations need to cultivate mechanisms for dispute settlement as discussed in Chapter 3.

**Chapter 3:** For 46 years (as of 2008), Thailand had never openly protested against the 1962 judgment delivered by the International Court of Justice. However, Thailand drew a unilateral map to be used at one point when it had the opportunity to invade Cambodia. The map was written in "secret" codes to conceal Thailand's ambition to expand its territory into Cambodia.

Noppadon Pattama, former Minister of Foreign Affairs of Thailand, responded in an over-seven/eight-hour session in the Thai Parliament on 27 June 2008 that "*I would like to say that the 15 June 1962 brought grievance to all Thai people. I was only 1 year old so I was not well aware of what Thai people lost at the time. On that day, the ICJ rendered its judgment stating that the province in which the Temple of Preah Vihear is located belongs to Cambodia or that the Temple of Preah Vihear is situated in the territory under the sovereignty of Cambodia. We have nothing more to comment*

*on the reason why we lost the case. It is the principles of international laws – the Estoppels Law".* Referring to a letter Colonel Thanat Khoman, the then Minister of Foreign Affairs of Thailand sent to Mr. U Thant, Secretary General of the United Nations (who was a Burmese) which reads "*Thai Party reserves its present right or the future rights to claim back the Preah Vihear temple,"* Noppadon Pattama said "the judgment of the International Court of Justice allows Thailand to file a motion for review within 10 years. It's been 45 years now. It's all over".

According to Article 60 of the Statute of the ICJ, the judgment gives Thailand an opportunity to file a motion for review within 10 years, but Thailand did not file the motion in 1972. Therefore, Thailand has no permanently reserved rights under any international law for it to make claim over Preah Vihear temple or the area surrounding the temple.

